# បេឡាជាតិរបបសន្តិសុខសង្គម

# National Social Security Fund

## ព្រឹត្តិបត្រព័ត៌មាន

ប.ស.ស ឆ្នាំទី០៥ លេខ០៩ ឆ្នាំ២០១៥




ធានាសន្តិសុខប្រាក់ចំណូល | រួមចំណែកកាត់បន្ថយភាពក្រីក្រ | លើកកម្ពស់ស្ថិរភាពសង្គម

## អ្នកមានជួយអ្នកក្រ
## អ្នកមានសុខភាពល្អជួយអ្នកឈឺ



## សេវាសង្គ្រោះបន្ទាន់
## ២៤ ម៉ោង

## Hotline 1286

# មាតិកា

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិរបបសន្តិសុខសង្គម


១- របាយការណ៍សង្ខេបគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម..........២

២- លោក អ៊ុក សមវិទ្យា នាយក ប.ស.ស ចូលរួមរំលែកទុក្ខ និងនាំយកថវិកា ផ្តល់ជូនក្រុមគ្រួសារសពកម្មករស្លាប់ក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ដ៏រន្ធត់នៅខេត្តស្វាយរៀង..........៣

៣- បេឡាជាតិរបបសន្តិសុខសង្គម រៀបចំពិធីសំណេះសំណាលជាមួយសមាជិក និងអត្តគាហក(អ្នកនៅក្នុងបន្ទុក)..........៤

៤- មន្ត្រី ប.ស.ស ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុនៃរបបប្រាក់សោធន នៅប្រទេសថៃ..........៥

៥- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូន កម្មករនិយោជិត ដល់និយោជក ដែលមានទីតាំងស្ថិតក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល..........៦

៦- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ដល់និយោជក ស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល..........៧

៧- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក នៅខេត្តមណ្ឌលគិរី..........៨

៨- កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក នៅខេត្តកោះកុង..........៩

៩- កិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនដល់កម្មករនិយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល..........១០

១០- កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ដល់កម្មករនិយោជិតនៅរោងចក្រ JTH TEXTILE (CAMBODIA) INC..........១១

១១- ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត..........១២

១២- កិច្ចប្រជុំផ្សព្វផ្សាយអប់រំអំពីច្បាប់ចរាចរណ៍ផ្លូវគោកនៅរោងចក្រ BERRY APPEREL (CAMBODIA) CO.,LTD..១៤

១៣- កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ CAMBO HANSOMS LTD..........១៥

១៤- កម្មការិនីប្រមាណ១៣នាក់ រងរបួសក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដោយរថយន្តបុកជាមួយរថយន្ត នៅខេត្តកំពង់ស្ពឺ..........១៦

១៥- កម្មករ-កម្មការិនី ០៦នាក់ រងរបួសធ្ងន់ និងស្រាល ដោយរថយន្តបុកជាមួយរថយន្ត នៅខេត្តស្វាយរៀង..........១៧

១៦- ស្លាប់ ១៩នាក់ និងរបួសធ្ងន់ស្រាល ២០នាក់ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយ បង្កដោយរថយន្តក្រុងបុកជាមួយរថយន្តដឹកកម្មករ នៅខេត្តស្វាយរៀង..........១៨

១៧- សេចក្តីជូនដំណឹង ស្តីពីនីតិវិធីនៃការបង់ភាគទាន..........១៩

១៨- សេចក្តីជូនដំណឹង..........២០

១៩- បន្លែផ្លែឈើ ៧យ៉ាងល្អចំពោះសុខភាព..........២២

២០- ទស្សនៈគួរពិចារណា..........២៣

២១- ក្រុមប្រចាំការ HOTLINE 24 ម៉ោង..........២៤

២២- សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត..........២៥

២៣- អាសយដ្ឋានមន្ទីរពេទ្យដែលជាដៃគូរបស់បេឡាជាតិរបបសន្តិសុខសង្គម ២៤រាជធានី/ខេត្ត..........២៧






**រចនាសម្ព័ន្ធព្រឹត្តិបត្រ ប.ស.ស**

លោក អ៊ុក សមវិទ្យា នាយក ប.ស.ស

ចាងហ្វាង លោក ជាវ ប៊ុនរិទ្ធ

និពន្ធនាយក លោក ឌួង ច័ន្ទតារា

និពន្ធនាយករង លោក ចាយ សំណាង

លោក ស្រី សៅ

លេខានិពន្ធ លោកស្រី សុខ សូរ្យស្មី

កញ្ញា យ៉ែម ចន្ធូ

ផ្នែកកុំព្យូទ័រ លោក យុន វិចិត្រ

លោក ពៅ សុវណ្ណារ៉ា

# រចនាសម្ព័ន្ធគ្រប់គ្រងបេឡាជាតិរបបសន្តិសុខសង្គម



# លោក អ៊ុក សមវិទ្យា នាយក ប.ស.ស ចូលរួមរំលែកទុក្ខ និងនាំយកថវិកា ផ្តល់ជូនក្រុមគ្រួសារសពកម្មករស្លាប់ ក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់ នៅខេត្តស្វាយរៀង

នារសៀលថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ កន្លងមកនេះលោក អ៊ុក សមវិទ្យា នាយកបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងសហការី បានអញ្ជើញទៅចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពកម្មករទាំង ១៩គ្រួសារ និងនាំយកប្រាក់វិភាជន៍ជាសោហ៊ុយបូជាសពផ្តល់ជូនក្រុមគ្រួសារជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត ក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ជាគ្រោះថ្នាក់ការងារ



គ្រួសារសពជនរងគ្រោះដែលស្លាប់ក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅខេត្តស្វាយរៀង

ដោយរថយន្តក្រុងបុកជាមួយរថយន្តដឹកកម្មករ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ នៅខេត្តស្វាយរៀង ដោយក្នុងមួយគ្រួសារនៃសពម្នាក់ទទួលបានថវិកាចំនួន៩លានរៀលសម្រាប់ជាវិភាជន៍បូជាសព។

ទន្ទឹមនឹងនោះដែរ លោកនាយក បានផ្សព្វផ្សាយពីរបបសន្តិសុខសង្គម សម្រាប់ផ្តល់ជូនជនរងគ្រោះរួមមាន៖ ថ្លៃដឹកជញ្ជូនសព, តាវកាលិកឧត្តរជីវី (អត្ថប្រយោជន៍ដល់អ្នកដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ) ដែលមានដូចជា ប្រពន្ធ ឬប្តី កូន និងជនចាស់ជរាជាដើម។ ដោយឡែកជនរងគ្រោះដែលរងរបួសធ្ងន់ និងស្រាលត្រូវទទួលបានសេវាពី ប.ស.ស ដូចជា៖ សេវា



លោក អ៊ុក សមវិទ្យា អញ្ជើញចូលរួមរំលែកទុក្ខ ដល់ក្រុមគ្រួសារសពជនរងគ្រោះ

សង្គ្រោះបន្ទាន់, ការចំណាយលើការព្យាបាលរហូតជាសះស្បើយ ប្រាក់វិភាជន៍ សម្រាប់អ្នកថែទាំ និងអ្នកចាំថែរក្សាជនរងគ្រោះ, ប្រាក់បំណាច់ប្រចាំថ្ងៃ, ក្នុងករណីរងគ្រោះរហូតដល់ពិការភាពក្រោម ២០% ប.ស.ស នឹងបើកប្រាក់វិភាជន៍ផ្តាច់តែម្តង គត់, បើពិការភាពចាប់ពី ២០% ឡើង ប.ស.ស នឹងបើកប្រាក់ធនលាភ (បើកផ្តល់ប្រាក់ឧបត្ថម្ភឱ្យមួយជីវិត)។ បើពិការភាពជនរងគ្រោះនឹងទទួលបានឧបករណ៍សិប្បនិម្មិត អត្ថប្រយោជន៍ដទៃទៀត និងផ្តល់សេវាបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈឡើងវិញផងដែរ។

បន្ថែមពីនេះ លោកនាយក បានអំពាវនាវដល់បងប្អូនកម្មករនិយោជិតត្រូវមានការប្រុងប្រយ័ត្នពេលធ្វើដំណើរទៅ និងត្រឡប់មកពីកន្លែងធ្វើការ។ ជាពិសេសអ្នកបើកបរដឹកកម្មករ ត្រូវគោរពច្បាប់ចរាចរណ៍ និងត្រូវពិនិត្យយានយន្តជាប្រចាំមុនពេលចេញដំណើរ។





សកម្មភាពចូលរួមរំលែកទុក្ខ និងនាំយកប្រាក់វិភាជន៍សម្រាប់បូជាសពផ្តល់ជូនក្រុមគ្រួសារសព (អ្នកនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ)

# បេឡាជាតិរបបសន្តិសុខសង្គម រៀបចំពិធីសំណេះសំណាលជាមួយសមាជិក និងអត្តគាហក (អ្នកនៅក្នុងបន្ទុក)

កាលពីថ្ងៃទី២៩ខែឧសភាឆ្នាំ២០១៥បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) រៀបចំពិធីសំណេះសំណាលជាមួយសមាជិក និងអត្តគាហក(អ្នកនៅក្នុងបន្ទុក)ដែលកំពុងត្រូវទទួលតាវកាលិក បាត់បង់សមត្ថភាពការងារអចិន្ត្រៃ និងឧត្តរជីវី ក្រោមអធិបតីភាព លោក អ៊ុក សមវិទ្យា នាយក ប.ស.ស នាយករង ប្រធាន អនុប្រធានការិយាល័យ ព្រមទាំងមានការអញ្ជើញចូលរួមពីសមាជិក ប.ស.ស និងអត្តគាហក នៅទូទាំងប្រទេស។ បច្ចុប្បន្ន ប.ស.ស មានសាខានៅតាមបណ្តារាជធានីខេត្តទាំង ២៤/២៥ និងមាន



ការចូលរួមរបស់សមាជិក និងអត្តគាហក (អ្នកនៅក្នុងបន្ទុក) ក្នុងពិធីសំណេះសំណាល

សហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាសរុបចំនួន៧.៣៨៥ សហគ្រាស (អនុវត្តចំពោះសហគ្រាស ដែលមានកម្មករនិយោជិត ចាប់ពី០៨ នាក់ឡើង) និងមានសមាជិកសរុបចំនួន ១.០៥១.៥០៨នាក់ ជាពិសេសមានមន្ទីរពេទ្យដែលជាដៃគូរបស់ បេឡាជាតិរបបសន្តិសុខសង្គម ចំនួន៨៨ សម្រាប់ផ្តល់សេវាព្យាបាលជូនកម្មករ-កម្មការិនី នៅពេលដែលមានគ្រោះថ្នាក់ការងារ។





លោក អ៊ុក សមវិទ្យា នាយក ប.ស.ស អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល ជាមួយសមាជិក ប.ស.ស និងអត្តគាហក (អ្នកនៅក្នុងបន្ទុក)

ពេលដែលកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ (ជាគ្រោះថ្នាក់ការងារ) គាត់នឹងទទួលបានតាវកាលិកពី ប.ស.ស មានដូចជា៖ (ការព្យាបាលរហូតជាសះស្បើយ, ប្រាក់បំណាច់ប្រចាំថ្ងៃ, គ្រោះថ្នាក់ក្រោម២០% ជាវិភាជន៍, ចាប់ពី២០% ឡើងជាធនលាភសោហ៊ុយបូជាសព, ធនលាភឧត្តរជីវី, ការស្តារលទ្ធភាពពលកម្ម)។ ចាប់តាំងពីដំណើរការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ រហូតមក ដល់ពេលបច្ចុប្បន្ននេះ ប.ស.ស បានផ្តល់សេវាព្យាបាលជូនកម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារ បានចំនួន ៨៣.៦១២នាក់ ក្នុងចំណោមជនរងគ្រោះទាំងនោះ មានអ្នកស្លាប់ចំនួន ៣៩៦នាក់ របួសធ្ងន់ចំនួន ៤.៨៨១នាក់ របួសស្រាលចំនួន ៧៨៣៣៥នាក់។ ពិធីសំណេះសំណាលនេះវាពិតជាមានសារៈសំខាន់ណាស់ ព្រោះវាបានបង្ហាញពីការយកចិត្តទុកដាក់ និងសួរសុខទុក្ខដល់បងប្អូនកម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារ និងអ្នកនៅក្នុងបន្ទុកផ្ទាល់ អំពីការលំបាករបស់ពួកគាត់ និងចូលរួមជាយោបល់ ឬសំណូមពរ ដើម្បីកែលំអរសេវាកម្មរបស់បេឡាជាតិរបបសន្តិសុខសង្គមឱ្យបានកាន់តែប្រសើរថែមទៀត៕

# មន្ត្រីប.ស.សចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និង ចាត់ចែងហិរញ្ញវត្ថុនៃរបបប្រាក់សោធន នៅប្រទេសថៃ

ប.ស.ស បានដាក់ឱ្យដំណើរការជាស្ថាពរ និងទទួលបានជាផ្លែផ្កា នូវរបបធានារ៉ាប់រងហានិភ័យការងារ(គ្រោះថ្នាក់ការងារ) ដែលការពារ និងព្យាបាលកម្មករនិយោជិតបានតែមួយចំហៀងខ្លួនប៉ុណ្ណោះ។ នៅមួយចំហៀងខ្លួនទៀតគឺរបបថែទាំសុខភាព និងរបបប្រាក់សោធន ដែលកម្ពុជាមិនទាន់បានអនុវត្តនៅឡើយ។

បច្ចុប្បន្នបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បាននឹងកំពុងរៀបចំបង្កើតបទដ្ឋានគតិយុត្ត និងបែបបទ នៃគោលការណ៍




ទិដ្ឋភាពចូលរួមក្នុងវគ្គបណ្តុះបណ្តាល




គ្រឹះផ្សេងៗក្នុង និងក្រៅប្រទេស ដើម្បីដាក់ឱ្យដំណើរការរបបប្រាក់សោធនសម្រាប់កម្មករនិយោជិតនាពេលឆាប់ៗខាងមុខនេះ ដើម្បីឱ្យពួកគាត់មានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ។

ស្របពេលជាមួយគ្នានេះ ប.ស.ស បានបញ្ជូនមន្ត្រីជំនាញចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុនៃរបបប្រាក់សោធន នៅប្រទេសថៃ។ វគ្គបណ្តុះបណ្តាលសង្កត់ធ្ងន់ និងផ្តោតអារម្មណ៍ខ្លាំងទៅលើការគ្រប់គ្រង និងចាត់ចែងផ្នែកហិរញ្ញវត្ថុចំពោះរបបប្រាក់សោធន ដែលក្នុងនោះមាន៖

- នីតិវិធី និងបែបបទនៃការរៀបចំសម្រាប់ដំណើរការរបបប្រាក់សោធន
- ការរៀបចំគោលនយោបាយវិនិយោគសម្រាប់ប្រាក់សោធន
- ការវិភាគលើដំណើរការអនុវត្តរបបប្រាក់សោធន
- ការសិក្សាអំពីទិន្នន័យប្រជាសាស្ត្រសម្រាប់វាយតម្លៃទៅលើការអនុវត្តរបបនេះ ។
- ការសិក្សាអំពីទិន្នន័យសេដ្ឋកិច្ចជាតិ ដើម្បីប្រៀបធៀបនឹងការប្រមូលភាគទានរបបប្រាក់សោធននេះដែរ។

ម្យ៉ាងទៀត នៅក្នុងវគ្គនេះ ព្រះរាជាណាចក្រថៃឡង់ក៏បានចែករំលែកបទពិសោធន៍ចំពោះការអនុវត្តរបបប្រាក់សោធន ដែលប្រទេសនេះ បាននឹងកំពុងដាក់ឱ្យដំណើរការជាយូរឆ្នាំណាស់មកហើយ។ ដែលក្នុងនោះមានរបបប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិលសម្រាប់វិស័យឯកជន និងសម្រាប់ប្រជាពលរដ្ឋគ្រប់គ្រងដោយក្រសួងសុខាភិបាល ។

ប្រជាជនដែលគ្រប់គ្រង ដោយក្រសួងសុខាភិបាល គឺមានគោលនយោបាយផ្តល់ប្រាក់៣០០ Bath (សម្រាប់វិស័យមិនរៀបរយរបស់រដ្ឋាភិបាលប្រទេសខ្លួន)៕



ការថតរូបអនុស្សាវរីយ៍ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល

# កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យ ការងារជូនកម្មករនិយោជិត ដល់និយោជក ដែលមានទីតាំងស្ថិតក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល

ដើម្បីពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ នៅសាលប្រជុំសាលាក្រុងតាខ្មៅ ខេត្តកណ្តាល។

កិច្ចប្រជុំធ្វើឡើងក្រោមការដឹកនាំដោយ លោក ម៉េង ហុង នាយករង ប.ស.ស ការចូលរួមពីប្រធានសាខា ប.ស.ស ខេត្តកណ្តាល តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត និងលោក លោកស្រី ជានិយោជក នាយក ម្ចាស់ ឬតំណាងសហគ្រាសគ្រឹះស្ថាន ជាច្រើនរូបទៀត។



លោក ម៉េង ហុង នាយករង ប.ស.ស ចូលរួមជាអធិបតីក្នុងកិច្ចប្រជុំ

គោលបំណង នៃកិច្ចប្រជុំផ្តោតសំខាន់ទៅលើការពង្រឹងសេវារបស់មន្ទីរពេទ្យ សេវារបស់ធនាគារអេស៊ីលីដាភីអិលស៊ី សេវារបស់សាខា ប.ស.ស ខេត្ត និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀត ដូចដែលមានចែងក្នុងច្បាប់ជាធរមានក្នុងន័យបង្កើនការយល់ដឹងក្នុងការអនុវត្ត និងសិទ្ធិក្នុងការទទួលបានតាវកាលិក។ ជាពិសេស ជាផ្នែកមួយដ៏សំខាន់ដែលមានការចូលរួមមកពីគ្រប់ភាគី ក្នុងការដោះស្រាយរួមគ្នា ដើម្បីអភិវឌ្ឍន៍កិច្ចដំណើរការប្រព្រឹត្តទៅរបស់ ប.ស.ស ឱ្យកាន់តែល្អ និងមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

កិច្ចប្រជុំនេះដែរ ក៏បានបង្ហាញពីនីតិវិធី នៃការផ្តល់តាវកាលិកហានិភ័យការងារ ការសម្របសម្រួលនៅមន្ទីពេទ្យ បញ្ហាប្រឈម និងដំណោះស្រាយដែលមានដូចជា៖ តាវកាលិកហានិភ័យការងារ, សិទ្ធិទទួលបានតាវកាលិក, លក្ខខណ្ឌទទួលបានតាវកាលិក, ការគណនាតាវកាលិក, ការយល់ព្រមចំពោះការទាមទារតាវកាលិក, ទោសប្បញ្ញាត្តិ, នីតិវិធីអនុវត្ត និងបែបបទ នៃការទាមទារតាវកាលិក។ បែបបទស្តីពីការចុះបញ្ជិកា ការប្រមូលភាគទាន ការចុះអធិការកិច្ច និងការអង្កេតគ្រោះថ្នាក់មានដូចជា៖ ការចុះបញ្ជិកាសហគ្រាសគ្រឹះស្ថាននៅ ប.ស.ស, ការបង់ភាគទានមក ប.ស.ស, ព័ត៌មានពីចំនួនកម្មករនិយោជិតមិនគ្រប់ ឬរាយការប្រាក់ឈ្នួលជាប់ភាគទានមិនទាន់បានត្រឹមត្រូវមកកាន់ប.ស.ស, សារៈសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រកំណើត ឬអត្រានុកូលដ្ឋានរបស់កម្មករនិយោជិត, ការប្រតិបត្តិការជាមួយ ប.ស.ស តាមរយៈ Bank System, ទោសប្បញ្ញត្តិ, ការចុះអធិការកិច្ច, ការអង្កេតគ្រោះថ្នាក់ការងារ។

ជាចុងក្រោយមុននឹងបញ្ចប់កិច្ចប្រជុំ លោក ម៉េង ហុង បានផ្តាំផ្ញើចំពោះរោងចក្រ សហគ្រាសគ្រឹះស្ថាន រាល់ពេលមានបញ្ហាផ្សេងទាក់ទងការផ្តល់សេវារបស់ ប.ស.ស អាចធ្វើការ រាយការណ៍មកកាន់ស្នាក់ការកណ្តាល តាមរយៈលេខទូរស័ព្ទ ១២៨៦ ដោយឥតគិតថ្លៃ។ លោកក៏បានសំណូមពរឱ្យសហគ្រាស គ្រឹះស្ថាន ធ្វើការប្រកាសពីចំនួនកម្មករនិយោជិត និងការបង់ភាគទានឱ្យបានត្រឹមត្រូវ ព្រោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារអធិការកិច្ចចម្រុះ ដើម្បីចុះត្រួតពិនិត្យតាមបណ្តារោងចក្រ សហគ្រាស ទាំង២៥រាជធានី/ខេត្ត៕



សិក្ខាកាមដែលជាតំណាងនិយោជក សហជីពចូលរួមក្នុងកិច្ចប្រជុំ

# កិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិក ហានិភ័យការងារជូនកម្មករនិយោជិត ដល់និយោជក ស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល




លោក ម៉េង ហុង នាយករង ប.ស.ស អញ្ជើញជាកិត្តិយសក្នុងកិច្ចប្រជុំ



ដើម្បីបម្រើសេវាសាធារណៈជូន ដល់កម្មករនិយោជិតបានរលូន និងឆាប់រហ័សទៅបាន លុះត្រាតែនិយោជកអនុវត្តការងារឱ្យបានខ្ជាប់ខ្ជួន នូវអ្វីដែលក្រុមជំនាញបានផ្សព្វផ្សាយ។

កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ នៅស្រុកមុខកំពូល ខេត្តកណ្តាល បេឡាជាតិរបបសន្តិសុខសង្គម បានបើកកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិកហានិភ័យការងារជូន ដល់កម្មករនិយោជិត ក្រោមការដឹកនាំរបស់ លោក ម៉េង ហុង នាយករង ប.ស.ស មន្ត្រីក្រោមឱវាទ លោកអភិបាលរងស្រុកមុខកំពូល និងមានការចូលរួមពីលោក លោកស្រី ដែលជាតំណាង ម្ចាស់សហគ្រាសគ្រឹះស្ថាន ជាច្រើននាក់ទៀត។

ក្នុងឱកាសនោះ លោកនាយករង បានបញ្ជាក់អំពីគោលបំណងនៃកិច្ចប្រជុំគឺផ្តោតទៅលើសេវារបស់មន្ទីរពេទ្យសេវារបស់ធនាគារដែលចុះកិច្ចសន្យាជាមួយ ប.ស.ស (អេស៊ីលីដា) ការអនុវត្តការងាររបស់និយោជក និងការផ្តល់អត្ថប្រយោជន៍របស់ ប.ស.ស ផ្សេងទៀតជូនដល់កម្មករនិយោជិតដូចបានចែងក្នុងច្បាប់ ស្តីពីការងារ។ លោកបន្ថែមថានិយោជកត្រូវយកចិត្តទុកដាក់នូវអ្វីដែលក្រុមជំនាញបានណែនាំ ហើយយកទៅអនុវត្តឱ្យបានល្អ និងមានប្រសិទ្ធភាពក្នុងនោះមានបែបបទ និងវិធីសាស្ត្រផ្សេងៗទាក់ទងនឹងការការពារសិទ្ធិ និងការធ្វើចរាចរណ៍លិខិតស្នើសុំ ឬទាមទារនៃការផ្តល់អត្ថប្រយោជន៍របស់ប.ស.សជូនដល់កម្មករនិយោជិតផងដែរ។

លោក កែវ ប៊ុនណា ប្រធានការិយាល័យតាវកាលិក បានលើកឡើងអំពីការអនុវត្តការងារជំនាញមួយចំនួន និងចំណុចប្រឈមខ្លះដែលទាក់ទងគ្នាទៅនឹងអ្នកផ្តល់សេវា (ប.ស.ស) និងអ្នកទទួលសេវា (កម្មករនិយោជិត) ដែលទាមទារឱ្យពួកគាត់ និងនិយោជកជួយសហការឱ្យបានគ្រប់ជ្រុងជ្រោយ ឬឱ្យបានគ្រប់គ្រាន់នូវអ្វីដែលប.ស.ស បានទាមទារ។

បន្ទាប់ពីនេះដែរ លោក ម៉េង ហុង នាយករង បានលើកឡើងអំពីចំណុចប្រឈមខ្លះនៃសេវាមន្ទីរពេទ្យ គឺមកពីនិយោជកមិនបានផ្តល់ដំណឹងទាន់ពេលវេលា និងការបញ្ជូនឯកសារជនរងគ្រោះទៅមន្ទីរពេទ្យមិនគ្រប់គ្រាន់ជាដើម។ ការអនុវត្តនិយោជក (ការផ្តល់របាយការណ៍ចំនួនកម្មករមិនគ្រប់គ្រាន់ និងរបាយការណ៍ប្រាក់បៀវត្សរ៍មិនត្រឹមត្រូវ) ហេតុផលនេះ គឺជះឥទ្ធិពលអាក្រក់ ឬខាតបង់ប្រយោជន៍ ដល់និយោជកខ្លួនឯងទៅវិញទេ។

ជាចុងក្រោយនៃកិច្ចប្រជុំ លោក ម៉េង ហុង បានផ្តាំផ្ញើរ ដល់និយោជក ឬតំណាងឱ្យស្វែងយល់ និងប្រតិបត្តិតាមនូវអ្វីដែលផ្នែកជំនាញបានណែនាំ ដើម្បីមានភាពរលូនក្នុងការងារ និងជួយពន្យល់ ដល់កម្មករឱ្យបានយល់អំពីសិទ្ធិដែលខ្លួនត្រូវទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ឱ្យបានច្បាស់ផងដែរ៕



ការអញ្ជើញចូលរួមរបស់សិក្ខាកាមក្នុងកិច្ចប្រជុំ

# កិច្ចប្រជុំស្តីពីការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក នៅខេត្តមណ្ឌលគិរី

កាលពីព្រឹកថ្ងៃច័ន្ទទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គម បានអញ្ជើញសហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅក្នុងខេត្តមណ្ឌលគិរី មកចូលរួមប្រជុំស្តីពីការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក ជូនកម្មករនិយោជិត នៅសណ្ឋាគាររស្មីអរុណរះរីសត ដែលមានទីតាំងស្ថិតនៅភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។



ការធ្វើបទបង្ហាញរបស់ លោក ជាវ ប៊ុនរិទ្ធ ស្តីពីគោលនយោបាយថ្មីៗ



កិច្ចប្រជុំនេះរៀបចំឡើងក្រោមអធិបតីភាព លោក ម៉េង ហុង នាយករង ប.ស.ស និងសាខា ប.ស.ស ខេត្តមណ្ឌលគិរី បានធ្វើការបង្ហាញពីការយកចិត្តទុកដាក់ពីការបម្រើសេវាជូនកម្មករនិយោជិត នៅពេលពួកគាត់ទទួលរងគ្រោះថ្នាក់ដោយសារការងារ និងជំរុញឱ្យមន្ត្រីសាខាប.ស.សខេត្ត ត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយរាល់បញ្ហារបស់និយោជក ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន ជាពិសេសធ្វើការដោះស្រាយឱ្យទាន់ពេលវេលា ក្នុងការផ្តល់សេវាជូនកម្មករនិយោជិត។

ក្នុងឱកាសនោះលោក ជាវ ប៊ុនរិទ្ធ បានលើកឡើងថា ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសរុបចំនួន ៨៨ សម្រាប់ផ្តល់សេវាជូនកម្មករនិយោជិត នៅពេលជួបប្រទះនូវឧបទ្ទវហេតុគ្រោះថ្នាក់ការងារ។ ដែលគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់កើតឡើងនៅពេលកំពុងធ្វើការ នៅពេលធ្វើដំណើរទៅ និងត្រឡប់មកពីកន្លែងធ្វើការមកផ្ទះ និងជំងឺវិជ្ជាជីវៈ។

លោកបន្តថានៅឆ្នាំ២០១៥នេះ បេឡាជាតិរបបសន្តិសុខសង្គម បានចុះផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងសេវា នៃការផ្តល់តាវកាលិកហានិភ័យការងារជូនកម្មករនិយោជិត ឱ្យបាន២៥ រាជធានី/ខេត្ត ដោយធ្វើការផ្សព្វផ្សាយអប់រំណែនាំ អំពីការបង្ការគ្រោះថ្នាក់ការងារត្រូវយកចិត្តទុកដាក់ពីបញ្ហាសុខភាព សុវត្ថិភាព និងអនាម័យរបស់កម្មករនិយោជិត និងសុវត្ថិភាពក្នុងពេលធ្វើដំណើរពីផ្ទះមកកន្លែងធ្វើការ និងពីកន្លែងធ្វើការមកផ្ទះផងដែរ៕



សិក្ខាកាមដែលជាតំណាងសហគ្រាស គ្រឹះស្ថានចូលរួមក្នុងអង្គពិធី

# កិច្ចប្រជុំស្តីពីការផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងពង្រឹងការផ្តល់សេវាតាវកាលិក នៅខេត្តកោះកុង

ការពង្រឹងនៃការផ្តល់អត្ថប្រយោជន៍ ដល់កម្មករនិយោជិត បានរលូន និងមានប្រសិទ្ធភាព លុះត្រាតែនិយោជកយកចិត្តទុកដាក់អនុវត្តឱ្យបានល្អប្រសើរ និងសហការឱ្យបានស៊ីជម្រៅជាមួយការិយាល័យជំនាញរបស់ ប.ស.ស។

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ នៅសណ្ឋាគារកុងស៊ីធី ខេត្តកោះកុង បេឡាជាតិរបបសន្តិសុខសង្គម បានបើកកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយ នៃការពង្រឹងសេវាផ្តល់តាវកាលិក



លោក ម៉េង ហុង នាយករង ប.ស.ស ឡើងធ្វើបទបង្ហាញក្នុងកិច្ចប្រជុំ



ការឡើងបញ្ចេញមតិរបស់សិក្ខាកាមក្នុងអង្គពិធី

ហានិភ័យការងារជូនកម្មករនិយោជិត ក្រោមអធិបតីភាព លោក ម៉េង ហុង នាយករង ប.ស.ស លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ មន្ត្រីក្រោមឱវាទ និងមានការចូលរួមពីលោក លោកស្រីតំណាង ម្ចាស់សហគ្រាសគ្រឹះស្ថាន ជាច្រើននាក់ទៀត។

លោក ម៉េង ហុង នាយករង បានលើកឡើងអំពីចំណុចប្រឈមខ្លះនៃសេវាមន្ទីរពេទ្យ គឺបញ្ហាកើតឡើងគួបផ្សំនឹងនិយោជកមិនបានផ្តល់ដំណឹងមក ប.ស.ស ឱ្យបានទាន់ពេលវេលា និងការបញ្ជូនឯកសារជនរងគ្រោះទៅមន្ទីរពេទ្យមិនទាន់គ្រប់គ្រាន់។ នេះជាបញ្ហាមួយ ដែលនាំឱ្យមានការយឺតយ៉ាវក្នុងការព្យាបាល និងទាមទារសំណង។ មួយវិញទៀតការអនុវត្តរបស់និយោជក (ការផ្តល់របាយការណ៍ចំនួនកម្មករមិនគ្រប់គ្រាន់ និងការរាយការណ៍ប្រាក់បៀវត្សរ៍ត្រឹមត្រូវ) ក៏ជះឥទ្ធិពលអាក្រក់ដល់កិត្តិយស ឬខាតបង់ប្រយោជន៍ ដល់និយោជកខ្លួនឯងផងដែរ។

ក្នុងឱកាសនោះ លោកនាយករងក៏បានជម្រាបជូនអង្គប្រជុំអំពីទំនាក់ទំនងរដ្ឋបាលរវាងនិយោជក និងប.ស.ស ដែលពេលខ្លះមិនបានធ្វើការងារឱ្យបានស៊ីជម្រៅ។ ដែលនេះជាភាពចន្លោះប្រហោងរបស់និយោជកឬតំណាង។ លោកបានបន្តណែនាំអំពីរបៀបទំនាក់ទំនងបង់ភាគទាន និងការទាមទារសំណង នៃសេវារបស់ធនាគារដែលចុះកិច្ចសន្យាជាមួយ ប.ស.ស (អេស៊ីលីដា) ផងដែរ។ លោកបន្តថា ឥឡូវនេះនិយោជកមានភាពងាយស្រួលក្នុងការបង់ភាគទាន ដោយអាចធ្វើការនៅហ្នឹងកន្លែង មិនបាច់ទៅធនាគារផ្ទាល់ឡើយ។

លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ បានលើកឡើង អំពីការអនុវត្តការងារជំនាញមួយចំនួន និងចំណុចប្រឈមខ្លះដែលទាក់ទងគ្នាទៅនឹងអ្នកផ្តល់សេវា (ប.ស.ស) និងអ្នកទទួលសេវា (កម្មករនិយោជិត) ដែលទាមទារឱ្យពួកគាត់ និងនិយោជកជួយសហការឱ្យបានគ្រប់ជ្រុងជ្រោយ ឬឱ្យបានគ្រប់គ្រាន់នូវអ្វីដែលអ្នកជំនាញបានទាមទារ។ លោកក៏បានបញ្ជាក់បន្ថែមថា កន្លងមកការយឺតយ៉ាវនៃការផ្តល់អត្ថប្រយោជន៍ គឺមកពីបញ្ហានេះឯង។

ជាចុងក្រោយនៃកិច្ចប្រជុំលោក ម៉េង ហុង នាយករង បានផ្តាំផ្ញើដល់និយោជក ឬតំណាង ឱ្យស្វែងយល់ និងប្រតិបត្តិនូវអ្វីដែលផ្នែកជំនាញបានណែនាំ ដើម្បីមានភាពរលូនក្នុងការងារ និងជួយពន្យល់ដល់កម្មករ ឱ្យបានយល់អំពីសិទ្ធិដែលខ្លួនត្រូវទទួលបានអត្ថប្រយោជន៍ ពី ប.ស.ស ឱ្យបានច្បាស់ផងដែរ៕



សិក្ខាកាមដែលជាតំណាងម្ចាស់សហគ្រាស គ្រឹះស្ថានចូលរួមក្នុងកិច្ចប្រជុំ

# កិច្ចប្រជុំ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងការពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារជូនដល់កម្មករនិយោជិត នៅស្រុកអង្គស្នួល ខេត្តកណ្តាល



លោក កែវ ប៊ុនណា អញ្ជើញជាកិត្តយសក្នុងកិច្ចប្រជុំ

ការចុះសំបុត្រអាពាហ៍ពិពាហ៍ ចំពោះកម្មករនិយោជិតដែលរៀបការហើយ ជាបញ្ហាសំខាន់បំផុតសម្រាប់អ្នកដែលនៅក្នុងបន្ទុកផ្ទាល់របស់ខ្លួន ទទួលបានអត្ថប្រយោជន៍ពី ប.ស.ស នៅពេលខ្លួនទទួលរងហានិភ័យការងារ (គ្រោះថ្នាក់ការងារ) រហូតដល់បាត់បង់ជីវិត។ បើមិនដូច្នេះទេ ប.ស.ស នឹងមិនផ្តល់ជូនទេ រីឯនិយោជកមិនបានរាយការណ៍ អំពីទិន្នន័យរបស់កម្មករនិយោជិតខ្លួនមិនបានត្រឹមត្រូវ និងទាន់ពេលវេលានឹងត្រូវទទួលការពិន័យ ឬទទួលទោសតាមច្បាប់ពីការងារ តាមផ្លូវតុលាការ។



ការធ្វើបទបង្ហាញរបស់លោក កែវ ប៊ុនណា ដល់សិក្ខាកាមក្នុងអង្គពិធី

ហេតុផលនេះហើយទើបកាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ប.ស.ស បានបើកកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយថ្មីៗ និងពង្រឹងសេវានៃការផ្តល់តាវកាលិកហានិភ័យការងារ នៅស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមកិច្ចដឹកនាំរបស់លោក ម៉េង ហ៊ុង នាយករងនៃ ប.ស.ស លោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ ប្រធានសាខា ប.ស.ស ខេត្ត លោក លោកស្រីតំណាងនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ជនរងគ្រោះ និងអ្នកនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ។

កិច្ចប្រជុំមានគោលបំណងផ្សព្វផ្សាយអំពីការប្រតិបត្តិគោលការណ៍ច្បាប់នានា របស់និយោជក ការដោះស្រាយសំណុចប្រឈម ការផ្តល់សេវាមន្ទីរពេទ្យ ការផ្តល់សេវាបង់ប្រាក់ និងទាមទារសំណងនៅធនាគារអេស៊ីលីដា សារៈសំខាន់ នៃការផ្តល់អត្ថប្រយោជន៍ និងចំណុចប្រឈមនៃការផ្តល់សេវារបស់ ប.ស.ស។

លោក ម៉េង ហ៊ុង នាយករង ប.ស.ស មានប្រសាសន៍ថា និយោជក មានផលប៉ះពាល់កិត្តិយស និងអត្ថប្រយោជន៍ យ៉ាងខ្លាំង ប្រសិនបើខ្លួនមិនបានគោរពតាមលក្ខខណ្ឌការងារ ដែលក្នុងនោះមានការរាយការណ៍ អំពីចំនួនកម្មករនិយោជិតមិនគ្រប់គ្រាន់ និងអំពីប្រាក់បៀវត្សរ៍មិនត្រឹមត្រូវ និងលក្ខខណ្ឌដ៏ទៃទៀត។

ក្នុងឱកាសនោះលោក ជាវ ប៊ុនរិទ្ធ ប្រធានការិយាល័យគោលនយោបាយ បានធ្វើបទបង្ហាញអំពីអត្ថ ប្រយោជន៍សំខាន់ៗនានា ដែល ប.ស.ស បានផ្តល់ជូនកម្មករ និយោជិតជាច្រើន។ ប.ស.ស បានផ្តល់តាមលក្ខខណ្ឌ និងតាមគោលការណ៍ និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗទៀត។ លោកបានអំពាវនាវដល់កម្មករនិយោជិតដែលបានរៀបការហើយត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍។ បើមិនអញ្ចឹងទេ អ្នកដែលនៅក្នុងបន្ទុកខ្លួនមិនមានសិទ្ធទទួលបានអត្ថប្រយោជន៍ពី ប.ស.ស ទេ នៅពេលខ្លួនទទួលរងគ្រោះថ្នាក់ រហូត ដល់បាត់បង់ជីវិត។

ជាទីបញ្ចប់នៃកិច្ចប្រជុំ លោកនាយរងបានមានប្រសាសន៍ណែនាំ និងធ្វើការផ្តាំផ្ញើដល់និយោជក ឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវអ្វីដែល ប.ស.ស និងផ្នែកពាក់ព័ន្ធបានណែនាំអំពីលក្ខខណ្ឌការងារ និងជម្រាបជូន អំពីទោសប្បញ្ញត្តិផ្សេងៗ ដើម្បីអនុវត្តឱ្យបានល្អប្រសើរផងដែរ។

ម្យ៉ាងទៀតតម្រូវឱ្យនិយោជកធ្វើការផ្សព្វផ្សាយបន្តដល់កម្មករនិយោជិតឱ្យបានដឹង និងបានយល់អំពីការផ្សព្វផ្សាយរបស់ ប.ស.ស ដល់កម្មករនិយោជិតរបស់ខ្លួនដូចជា៖ ការតម្រូវឱ្យកម្មករនិយោជិត ដែលរៀបការហើយត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍ទើបអ្នកនៅក្នុងបន្ទុកផ្ទាល់ទទួលបានអត្ថប្រយោជន៍ពី ប.ស.ស នៅពេលខ្លួនទទួលរងគ្រោះរហូតដល់បាត់បង់ជីវិត និងអត្ថប្រយោជន៍ផ្សេងៗទៀត៕



# កិច្ចប្រជុំផ្សព្វផ្សាយអប់រំ ដល់កម្មករនិយោជិតនៅរោងចក្រ JTH TEXTILE (CAMBODIA) INC

ការសន្លប់របស់កម្មករនិយោជិត អាចកើតមានឡើងជាច្រើនករណី។ ករណីខ្លះដោយសារការហូបចុកមិនគ្រប់គ្រាន់ ឬខ្វះជីវជាតិ ការធ្វើការច្រើនម៉ោង ការហូបចុកមិនមានអនាម័យ និងខ្លះទៀតដោយសារបរិយាកាសនៅក្នុង និងជុំវិញបរិវេណ ឬក្រៅកន្លែងធ្វើការ។

ការសន្លប់ គឺតែងមានលក្ខណៈមួយកើតឡើងពីតិចនាក់ទៅច្រើននាក់ ដែលអ្នកបច្ចេកទេសកំណត់ថា ជាជម្ងឺស្ទេហិហ្សង។ ជម្ងឺនេះធ្វើឱ្យបងប្អូនកម្មករមានអាការៈភ័យខ្លាច មានអារម្មណ៍តានតឹង ថប់ដង្ហើម ធីងធោងវិលមុខ ទន់ដៃទន់ជើង ហើយក៏ដួលសន្លប់តៗគ្នារហូត ដល់ច្រើននាក់តែម្តង។ មិនត្រឹមតែនៅស្រុកខ្មែរទេ គេសង្កេតឃើញមានកើតជម្ងឺនេះនៅបណ្តាប្រទេសជឿនលឿនលើពិភពលោកផងដែរ។

ស្របជាមួយគ្នានេះ កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅរោងចក្រ JTH TEXTILE (CAMBODIA) INC ស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់កំបូល ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ (ទ.ស.ប.ក) ដឹកនាំដោយ ឯកឧត្តមវេជ្ជបណ្ឌិត ប៉ុក វណ្ណថាត ប្រធានក្រុមការងារ បានធ្វើការផ្សព្វផ្សាយដល់និយោជក និងបងប្អូនកម្មករនិយោជិត និងសមាជិកពាក់ព័ន្ធឱ្យបានយល់ និងចេះដឹងអំពីការបង្ការ និងទប់ស្កាត់ជម្ងឺទាំងនេះកុំឱ្យកើតមានឡើងជាយថាហេតុតទៅទៀតបាន។

ឯកឧត្តមប្រធានក្រុមការងារ បានលើកឡើងថាការសន្លប់នេះអាចកើតឡើង ដោយសារនិយោជកមិនទាន់បានអនុវត្តនូវលក្ខណ្ឌការងារមិនទាន់បានល្អនៅឡើយ (ការឱ្យកម្មករធ្វើការថែមម៉ោងលើកកំណត់) អំពីអនាម័យ និងសុវត្ថិភាពការងារ (បញ្ហាគីមី, បញ្ហារូបសាស្ត្រ, បញ្ហាចិត្តសាស្ត្រសង្គម, បញ្ហាវិទ្យាសាស្ត្ររៀបចំការងារ, បញ្ហាមេកានិច, បញ្ហាជីវសាស្ត្រជាដើម។

ឯកឧត្តមវេជ្ជបណ្ឌិត ប៉ុក វណ្ណថាត ប្រធានក្រុមការងារបានជម្រាបជូន ដល់កម្មករនិយោជិតថា កន្លងមកមានការទទួលរងសន្លប់កើតឡើងជាច្រើនករណីដែលការសន្លប់នេះកើតឡើងពីតិចនាក់ទៅច្រើននាក់ កើតឡើងទៅតាមបណ្តារោងចក្រសហគ្រាសនានា ដែល ប.ស.ស ចាត់ទុកថាជាគ្រោះថ្នាក់ការងារ។ រាល់ការដឹកជញ្ជូន និងការព្យាបាលជនរងគ្រោះ គឺស្ថិតនៅក្រោមការចំណាយផ្ទាល់របស់បេឡាជាតិរបបសន្តិសុខសង្គម៕



ឯកឧត្តមវេជ្ជ. ប៉ុក វណ្ណថាត អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ



ការធ្វើបទបង្ហាញរបស់ លោក ជាវ ប៊ុនរិទ្ធ ក្នុងកិច្ចប្រជុំ



សកម្មភាពចូលរួមរបស់សិក្ខាកាមក្នុងអង្គពិធី

# ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត




លោកស្រី បុប្ផា ផានី អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ

នៅដើមឆ្នាំ២០១៥នេះ ដោយមើលឃើញអំពីស្ថានភាពគ្រោះថ្នាក់ចរាចរណ៍កើតមានជារៀងរាល់ថ្ងៃ ភាគច្រើនផ្តើមចេញពីអ្នកបើកបរមិនបានគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន ដោយមានការធ្វេសប្រហែស ការបើកបរល្មើសល្បឿន ការបើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងជាដើម ។

ដើម្បីធ្វើការកាត់បន្ថយនូវគ្រោះថ្នាក់ទាំងនេះ ទើបនៅក្នុងខែមិនា ឆ្នាំ២០១៥ កន្លងមក ក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិអ្នកបើកបរដឹកកម្មករនិយោជិតឱ្យបានយល់ដឹង និងគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឱ្យមានប្រសិទ្ធិភាព។ នៅក្នុងខែមីនា កន្លងមកនេះក្រុមការងារ បានចុះធ្វើការផ្សព្វផ្សាយអប់រំ តាមបណ្តារោងចក្រសហគ្រាស គ្រឹះស្ថានចំនួន០៥ ដែលមានរោងចក្រ Man OU Garment Co.,Ltd, Galey Global (Cambodia) Co.,Ltd, Royal Crowntex International INC, តំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ, និងរោងចក្រ Quint Major IndustrialC.,Ltd ស្ថិតក្នុងខេត្តកណ្តាល និងខេត្តព្រះសីហនុ។

កិច្ចប្រជុំផ្សព្វផ្សាយខាងលើ មានការអញ្ជើញចូលរួមជាអធិបតីពីថ្នាក់ដឹកនាំបេឡាជាតិរបបសន្តិសុខសង្គម បណ្តាក្រសួងជំនាញពាក់ព័ន្ធ ដែលមានសមាសភាពក្នុងក្រុមការងារ មន្ត្រីប៉ូលីសជំនាញសណ្តាប់ធ្នាប់ចរាចរណ៍ខេត្ត និយោជកឬតំណាង និងមានការចូលរួមពីបណ្តាអ្នកបើកបរជាច្រើននាក់ទៀត។



ការធ្វើបទបង្ហាញរបស់ លោកស្រី បុប្ផា ផានី ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក



សិក្ខាកាមដែលជាកម្មករនិយោជិតចូលរួមកម្មកិច្ចប្រជុំ



ជាកិច្ចបន្ទាប់គ្រូឧទ្ទេសនាម បានធ្វើបទបង្ហាញស្តីពីសុវត្ថិភាពលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោកថ្មី ផ្លាកសញ្ញា គំនូសបំព្រួញ សុជីវធម៌ក្នុងការបើកបរ ទោសប្បញ្ញត្តិផ្សេងៗ បច្ចេកទេសត្រួតពិនិត្យ និងថែទាំយានយន្ត និងវិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ។ ដូចជាៈ ពាក់មួកសុវត្ថិភាព និងខ្សែក្រវ៉ាត់សុវត្ថិភាពឱ្យបានត្រឹមត្រូវ បំរាមនៃការសេពគ្រឿងស្រវឹងក្នុងពេលបើកបរ បើកបរមិនឱ្យហួសល្បឿនកំណត់ ការជែងឬវ៉ាគ្នា ការមិនឱ្យធ្វើដំណើរតាមយានយន្តដែលផ្ទុកលើសចំណុះការចេះអធ្យាស្រ័យគ្នា ការគោរពសិទ្ធិអទិភាព ការមិនឱ្យប្រើទូរស័ព្ទដៃក្នុងពេលបើកបរ ការតម្រូវឱ្យមានប័ណ្ណបើកបរត្រឹមត្រូវ ការមិនឱ្យមានចំណាំងផ្លាតលើខ្លួន ឬយានយន្ត ក្នុងពេលធ្វើដំណើរពេលយប់ ឬកន្លែងគ្មានពន្លឺជាដើម។

ឆ្លៀតឱកាសនោះ សមាជិកក្រុមការងារ ក៏បានលើកឡើងពីគោលបំណង នៃកិច្ចចុះផ្សព្វផ្សាយអប់រំ និងស្រង់ស្ថិតិអ្នកបើកបរយានយន្ត ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង នូវចំនួនអ្នកបើកបរដឹកកម្មករនិយោជិត ដើម្បីឱ្យស្របតាមផែនការសកម្មភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដើម្បីចូលរួមផ្សព្វផ្សាយអប់រំ ទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ការងារ ដែលផ្តោតសំខាន់លើគ្រោះថ្នាក់ពេលធ្វើដំណើរពីកន្លែងធ្វើការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការផងដែរ៕



# កិច្ចប្រជុំផ្សព្វផ្សាយអប់រំ អំពីច្បាប់ចរាចរណ៍ផ្លូវគោក នៅរោងចក្រ
## BERRY APPEREL (CAMBODIA) CO.LTD



លោក ជាវ ប៊ុនរិទ្ធ អញ្ជើញជាកិត្តិយសក្នុងកិច្ចប្រជុំ



លោក ជាវ ប៊ុនរិទ្ធ អញ្ជើញឡើងធ្វើបទបង្ហាញក្នុងអង្គពិធី

ការបើកបរហួសល្បឿនកំណត់ ការបើកបរក្រោមឥទ្ធពលនៃគ្រឿងស្រវឹង ជាពិសេសការធ្វេសប្រហែស និងកត្តាគួបផ្សំដទៃទៀត អាចនាំមកនូវគ្រោះថ្នាក់ ឬទុក្ខសោកអស់មួយជីវិត។ហើយអ្នកបើកបរផ្ទាល់ នឹងត្រូវទទួលទោសតាមច្បាប់។ ទន្ទឹមនឹងនោះដែរ អ្នកបើកបរក៏តម្រូវឱ្យមានការហាត់រៀននៅតាមសាលាបើកបរឱ្យបានត្រឹមត្រូវ ដើម្បីយល់ដឹងអំពីច្បាប់ចរាចរណ៍ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ហេតុផលនេះហើយ ទើបកាលពីព្រឹកថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ក្រុមសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត បានផ្សព្វផ្សាយដល់អ្នកបើកបរដល់កម្មករនិយោជិតនៅរោងចក្រ BERRY APPEREL (CAMBODIA) CO.LTD ក្រោមការ ដឹកនាំប្រជុំដោយលោក កាំង មូនីកា អគ្គលេខាធិការរង និងជាសមាជិកក្រុមការងារ(ស.ផ.ក) លោកជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ និងមានការចូលរួមពីអ្នកបើកបរដឹកកម្មករនិយោជិត និងកម្មករនិយោជិតមួយចំនួនទៀត។

លោក កាំង មូនីកា បានធ្វើបទបង្ហាញដល់អ្នកបើកបរ អំពីច្បាប់ចរាចរណ៍ ដែលក្នុងនោះលោកសង្កត់ធ្ងន់ទៅលើបច្ចេកទេសថែទាំនិងត្រួតពិនិត្យយានយន្ត វិជ្ជាសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ និងវិធីសាស្ត្រផ្សេងៗទៀត ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ជាយថាហេតុនេះឱ្យស្ថិតនៅកម្រិតមួយទាបជាអប្បបរមា។

លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ ក៏បានលើកឡើងបន្ថែមអំពីហេតុផលដែលនាំឱ្យមានការផ្សព្វផ្សាយនេះ ដោយសារកន្លងមកគ្រោះថ្នាក់ចរាចរណ៍កើតមានឡើងជាញឹកញាប់ទៅលើបងប្អូនកម្មករនិយោជិតដោយសារអ្នកបើកបរគ្មានការប្រុងប្រយ័ត្ន ល្មើសល្បឿន បើកបរក្រោមឥទ្ធិពល នៃគ្រឿងស្រវឹង ហើយភាគច្រើនគ្មានប័ណ្ណបើកបរ និងកត្តាផ្សេងៗទៀត ដែលនាំឱ្យកើតមានគ្រោះថ្នាក់នេះ។

ចុងបញ្ចប់នៃកម្មវិធី លោក កាំង មូនីកា បានណែនាំបន្ថែមដល់អ្នកបើកបរ ឱ្យធ្វើអ្វីតាមការណែនាំរបស់ក្រុមការងារឱ្យបានខ្ជាប់ខ្ជួន ដើម្បីឱ្យការបើកបរមានសុវត្ថិភាពល្អ៕



សិក្ខាកាមដែលជាកម្មករនិយោជិតចូលរួមក្នុងអង្គពិធី

# កិច្ចប្រជុំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅរោងចក្រ CAMBO HANDSOMS LTD



មតិណែនាំរបស់លោក ជាវ ប៊ុនរិទ្ធ ដល់បងប្អូនអ្នកបើកបរ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្នុងអង្គពិធី

ដោយទទួលបានគោលការណ៍ពិសេសពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីសុំសិទ្ធិក្នុងការរៀបចំប្រឡង និងផ្តល់ប័ណ្ណបើកបរជូនអ្នកបើកបរដឹកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រ ដោយអនុវត្តតាមនីតិវិធី នៃការបណ្តុះបណ្តាលប្រឡង និងផ្តល់ប័ណ្ណបើកបរ ដែលមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី/ខេត្តចូលរួមសហការជាមួយក្រុមការងារ (ស.ផ.ក) ក្នុងការអនុវត្តផ្ទាល់នៅតាមរោងចក្រ។

ទើបក្នុងរយៈពេលនេះ ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ស្តីពីច្បាប់ ចរាចរណ៍ផ្លូវគោក នៅរោងចក្រ CAMBO HANDSOME CO.,Ltd ដែលស្ថិតនៅសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រោមការ ដឹកនាំប្រជុំដោយ លោកស្រី ប៉ែន សក្កូនី សមាជិកក្រុមការងារ និងជាប្រធានគម្រោងអប់រំ និងផ្សព្វផ្សាយ នៃអង្គការ HANDICAP INTERNATIONAL, លោក ជាវ ប៊ុនរិទ្ធ សមាជិកក្រុមការងារ និងជាប្រធានការិយាល័យគោលនយោបាយ ព្រមទាំងមានការចូលរួមពីសិក្ខាកាមដែលជាអ្នកបើកបរដឹកម្មករនិយោជិតជាច្រើននាក់ទៀត។

លោកស្រី ប៉ែន សក្កូនី បានធ្វើបទបង្ហាញពន្យល់ណែនាំពីសុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករ ដល់អ្នកបើកបរដឹកកម្មករឱ្យមានការប្រុងប្រយ័ត្ន ក្នុងពេលបើកបរ។ ត្រូវមានការយល់ដឹង និងត្រូវត្រួតពិនិត្យយានយន្តជាប្រចាំមុនពេលចេញដំណើរ។ ចំណែកអ្នកបើកបរម៉ូតូត្រូវគោរពច្បាប់ចរាចរណ៍ ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ ដើម្បីការពារអាយុជីវិត។ ក្នុងខណៈនោះដែរ គ្រូឧទ្ទេសនាមក៏បានពន្យល់ណែនាំពីគុណសម្បត្តិនៃការពាក់មួកសុវត្ថិភាព និងគុណវិបត្តិដែលប៉ះពាល់ដល់ជនរងគ្រោះនៃការមិនពាក់មួកសុវត្ថិភាព (ចំពោះអ្នកជិះម៉ូតូ)។

ជាមួយគ្នានេះដែរលោក ជាវ ប៊ុនរិទ្ធ បានធ្វើបទឧទ្ទេសនាមយ៉ាងក្បោះក្បាយពីគោលនយោបាយរបស់ ប.ស.ស ដែលបច្ចុប្បន្ននេះកំពុងធានារ៉ាប់រងគ្រោះថ្នាក់ការងារ ដល់កម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ដោយការងារ និងគ្រោះថ្នាក់ពេលកំពុងធ្វើដំណើរទៅនិងត្រឡប់មកពីធ្វើការ។ តាវកាលិក (អត្ថប្រយោជន៍) ដែលសហគ្រាស គ្រឹះស្ថាន និងសមាជិក (កម្មករនិយោជិត) អាចទទួលបានពី ប.ស.ស រួមមាន៖ ការសង្គ្រោះបន្ទាន់ការថែទាំ និងព្យាបាល ការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ការទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍ សោហ៊ុយបូជាសព តាវកាលិកឧត្តរជីវី សេវាបុននីតិសម្បទា និងការសម្របសម្រួលវិជ្ជាជីវៈឡើងវិញ៕



សិក្ខាកាមដែលជាអ្នកបើកបរដឹកកម្មករនិយោជិត និងតំណាងរដ្ឋបាលរោងចក្រចូលរួមក្នុងកិច្ចប្រជុំ

# កម្មការិនីប្រមាណ១៣នាក់ រងរបួសក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ដោយរថយន្តបុកជាមួយរថយន្ត នៅខេត្តកំពង់ស្ពឺ

នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ វេលាម៉ោង៦:៣០នាទី មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍មួយ នៅលើកំណាត់ផ្លូវជាតិលេខ៤ ម្តុំថ្នល់ទទឹង នៅទល់មុខរោងចក្រ Waifull Garment ដែលបង្កដោយរថយន្តដឹកកម្មករមួយគ្រឿងបានបើកទៅកៀ ជាមួយរថយន្តដឹកកម្មករមួយគ្រឿងទៀត ដែលជារថយន្តរបស់ជនរងគ្រោះបណ្តាលឱ្យបាក់ទ្រុង បង្កឱ្យកម្មការិនី ១៣នាក់ ទទួលរងរបួស។



សកម្មភាពនៃការជួយសង្គ្រោះរបស់គ្រូពេទ្យជូនជនរងគ្រោះ

កម្មការិនីដែលរងរបួសដោយគ្រោះថ្នាក់ចរាចរណ៍ទាំង ១៣នាក់ ខាងលើនេះបម្រើការងារនៅរោងចក្រ Maxlin, Master & Frank, Vano Industrial និងរោងចក្រ SCCL។ ចំពោះជនរងគ្រោះទាំង១៣នាក់ សាខា ប.ស.ស ខេត្ត បានចុះទៅជួយសម្រប





រូបភាពជនរគ្រោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ

សម្រួល និងបញ្ជូនជនរងគ្រោះទៅសម្រាកព្យាបាលនៅគ្លីនិកថ្នល់ទទឹង។

ក្នុងនោះមានជនរងគ្រោះម្នាក់មានសភាពធ្ងន់ធ្ងរពេក ទើបបានបញ្ជូនជនរងគ្រោះបន្តមកសម្រាកព្យាបាល នៅមន្ទីរពេទ្យកាលម៉ែត។ ចំពោះរាល់ការចំណាយលើមធ្យោបាយដឹកជញ្ជូន និង



សេវាព្យាបាល ជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

បេឡាជាតិរបបសន្តិសុខសង្គម បានអំពាវនាវដល់បងប្អូនកម្មករទាំងអស់ឱ្យមានការប្រុងប្រយ័ត្នទ្វេរដង ដើម្បីកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ដូចពាក្យស្លោកមួយបានពោលថា "ថ្ងៃនេះថ្ងៃស្អែកសុំកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍" ៕

# កម្មករ-កម្មការិនី ០៦នាក់ រងរបួសធ្ងន់ និងស្រាល ដោយរថយន្ត បុកជាមួយរថយន្ត នៅខេត្តស្វាយរៀង







រូបភាពជនរងគ្រោះសម្រាកព្យាបាលនៅមន្ទីរពេទ្យ

កាលពីវេលាម៉ោងប្រមាណជា ០៧ និង១០នាទី ព្រឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នេះបាន បង្កឱ្យកម្មករ-កម្មការិនីចំនួន ០៦នាក់ បានរង របួសធ្ងន់ និង ស្រាល។ ជនរងគ្រោះ ១. ឈ្មោះ សូ ផាត ភេទប្រុស អាយុ ៣១ ឆ្នាំ បម្រើការនៅក្រុមហ៊ុនស្មាតថេត (ខេមបូឌា) ២. ធួន សុវណ្ណា ភេទស្រី អាយុ ២៧ឆ្នាំ ៣. អ៊ុន ឡី ភេទស្រី អាយុ ២៧ឆ្នាំ ៤. ធូ សារ៉ា ភេទស្រី អាយុ ៣០ឆ្នាំ ៥. ញៀប រតនៈវិទ្យា ភេទ ប្រុស អាយុ ២៥ឆ្នាំ បម្រើការនៅក្រុមហ៊ុន អេលីត (ខេមបូឌា) ៦. ឈុំ កន ភេទស្រី អាយុ ២៤ឆ្នាំ បម្រើការនៅក្រុមហ៊ុន ជីហ្វា អេអ្វូខេ។

ករណីគ្រោះថ្នាក់ខាងលើបានកើតឡើងនៅតាមបណ្តោយផ្លូវ ជាតិលេខ១ នៅពីមុខខ្លោងទ្វារតំបន់សេដ្ឋកិច្ចពិសេសនាគរាជស្ថិត នៅភូមិព្រជប់ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង។ គ្រោះថ្នាក់នេះបង្កដោយរថយន្តដឹកកម្មករមួយគ្រឿង បើកចេញពី ទិសខាងត្បូងមកដល់ចំណុចកើតហេតុ ក៏បុករថយន្តដឹកកម្មករ មួយគ្រឿងទៀតពេញទំហឹង ក្នុងខណៈពេលដែលរថយន្តរបស់ ជនរងគ្រោះបានបន្ថយល្បឿនដើម្បីឱ្យកម្មករចុះ ដែលបណ្តាល ឱ្យកម្មករ-កម្មការិនី ០៥នាក់ របួសស្រាល និងម្នាក់ទៀតរង របួសធ្ងន់។

ភ្លាមៗនោះ សាខា ប.ស.ស ខេត្ត បានចុះទៅជួយសម្រប សម្រួល និងបញ្ជូនជនរគ្រោះ ០៥នាក់ទៅព្យាបាលនៅមន្ទីរពេទ្យ បង្អែកជីភូ ជនរងគ្រោះម្នាក់ទៀតត្រូវបញ្ជូនទៅគ្លីនិកផាសុខភាព១ តែដោយសារជនរងគ្រោះមានសភាពធ្ងន់ធ្ងរពេក គ្លីនិកបានបញ្ជូន បន្តមកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត។ រាល់ការចំណាយលើ មធ្យោបាយដឹកជញ្ជូន និងចំណាយលើការព្យាបាលជនរងគ្រោះ រហូត ដល់ជាសះស្បើយជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខ សង្គម។ ចំពោះគ្រោះថ្នាក់ខាងលើនេះ ជាគ្រោះថ្នាក់ការងារ ហើយ សហគ្រាស បានចុះបញ្ជិកាកម្មករនិយោជិតជាមួយ ប.ស.សរួច។

ទន្ទឹមនឹងនេះ បេឡាជាតិរបបសន្តិសុខសង្គមសូមអំពាវនាវដល់ បងប្អូនកម្មករនិយោជិត ត្រូវមានការប្រុងប្រយ័ត្នពេលធ្វើដំណើរ ទៅ និងត្រឡប់មកពីកន្លែងធ្វើការជាពិសេសអ្នកបើកបរដឹកកម្មករ ត្រូវគោរពច្បាប់ចរាចរណ៍ និងត្រូវពិនិត្យយានយន្តជាប្រចាំមុនពេល ចេញដំណើរ៕

# ស្លាប់ ១៩នាក់ និងរបួសធ្ងន់ស្រាល ២០នាក់ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយ បង្កដោយរថយន្តក្រុងបុកជាមួយរថយន្តដឹកកម្មករ នៅខេត្តស្វាយរៀង

ហេតុការណ៍គ្រោះថ្នាក់ចរាចណ៍ដ៏រន្ធត់មួយ នៅលើកំណាត់ផ្លូវជាតិលេខ១ ស្ថិតនៅក្នុងភូមិដើមពោធិ៍ ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ៦ និង៥០នាទីព្រឹក។ ហេតុការណ៍គ្រោះថ្នាក់នេះ បង្កដោយរថយន្តក្រុងក្រុមហ៊ុន (១៥ SH ស្លាកលេខ PP3C 6335) បើកបរដោយជនជាតិវៀតណាម ក្នុងទិសដៅពីលិចទៅកើតលុះមកដល់ចំណុចកើតហេតុ បានជែងរថយន្តមួយគ្រឿងផ្សេងទៀត ទើបមកបុករថយន្តដឹកកម្មករ ដែលបើកបញ្រ្ច្រាស់ទិសគ្នាចំពីមុខពេញទំហឹងបណ្តាលឱ្យកម្មករ-កម្មការិនីចំនួន១៩នាក់បានស្លាប់បាត់បង់ជីវិត និងរងរបួសធ្ងន់ស្រាលរហូតដល់ ២០នាក់។ ហេតុការណ៍នេះដែរ មន្ត្រីសាខា ប.ស.ស ខេត្តបានចុះទៅជួយសម្របសម្រួលបញ្ជូនជនរងគ្រោះទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកជីភូ, មន្ទីរពេទ្យខេត្តស្វាយរៀង និងមន្ទីរពេទ្យកាល់ម៉ែត។ ក្នុងឧបទ្ទវហេតុថ្នាក់ខាងលើនេះ ជាគ្រោះថ្នាក់ការងារ ហើយសហគ្រាសបានចុះបញ្ជិកាកម្មករនិយោជិតមកក្នុង ប.ស.ស។ កម្មករ-កម្មការិនីដែលស្លាប់ និងរបួសក្នុងហេតុការណ៍គ្រោះថ្នាក់ខាងលើជាសមាជិក ប.ស.ស និងត្រូវទទួលបានប្រាក់សោហ៊ុយបូជាសពក្នុងមួយគ្រួសារ ៤លានរៀលជាវិភាជន៍បូជាសព និងតាវកាលិកឧត្តរជីវី (អត្ថប្រយោជន៍ដល់អ្នកដែលនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះ) ដូចជាប្រពន្ធ ឬប្តី កូន ជនចាស់ជរាជាដើម។ ដោយឡែកចំពោះជនរងគ្រោះ ដែលរងរបួសធ្ងន់ស្រាលត្រូវទទួលបានសេវា ពីបេឡាជាតិរបបសន្តិសុខសង្គម ដូចជា៖ សេវាសង្គ្រោះបន្ទាន់, ការចំណាយលើការព្យាបាលរហូតជាសះស្បើយ, ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំ និងអ្នកចាំថែរក្សាជនរងគ្រោះ, ប្រាក់បំណាច់ប្រចាំថ្ងៃ, បើពិការភាពក្រោម ២០% ប.ស.ស នឹងបើកប្រាក់ឧបត្ថម្ភផ្តាច់ជូន, បើចាប់ពី ២០%ឡើង ប.ស.ស នឹងបើកប្រាក់ឧបត្ថម្ភជាប្រចាំខែមួយជីវិត រួមទាំងផ្តល់ជូនឧបករណ៍ សម្រាប់ជនពិការដូចជា ដៃ ជើងសិប្បនិម្មិត និងរទេះរុញជាដើម លើសពីនេះនឹងផ្តល់សេវាបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈឡើងវិញផងដែរ៕



ទិដ្ឋភាពគ្រោះថ្នាក់ចរាចរណ៍នៅខេត្តស្វាយរៀង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ១០/១៤ ប.ស.ស

# សេចក្តីជូនដំណឹង
## ស្តីពីនីតិវិធីនៃការបង់ភាគទាន

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានជ្រាបថា ដើម្បីសម្រួលដល់ដំណើរការនៃការបង់ភាគទាន ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម ៖

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

១- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ

២- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈសេវាកម្មអ៊ិនធើណែតប៊ែងឃីង (Internet Banking) ឬ សេវាកម្មយូនីធី (Unity) ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ តទៅ ។ រាល់ការចំណាយសេវាកម្មនេះជាបន្ទុកផ្ទាល់របស់និយោជក ។

៣- ចំពោះបង្កាន់ដៃបង់ភាគទាន របាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬ ឯកសារចាំបាច់នានា និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យ ប.ស.ស ឬ ផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

***បញ្ជាក់ ៖***

ចំពោះលោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានរួចហើយ ផ្ញើរបាយការណ៍កម្មករនិយោជិតតាមរយៈសារអេឡិចត្រូនិច ត្រូវមានឯកសារដូចជា ៖

- របាយការណ៍កម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច E-Form)
- លិខិតប្រកាសបង់ភាគទានហានិភ័យការងារ
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- តារាងបើកប្រាក់បៀវត្សកម្មករ និយោជិត (ទម្រង់អេឡិចត្រូនិច Payroll)

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ០០១/១៥ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក/លោកស្រី ជាម្ចាស់ ឬនាយក ឬតំណាងនៃសហគ្រាសគ្រឹះស្ថានដែលមានកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ការងារ ព្រមទាំងសាមីជនរងគ្រោះទាំងអស់ដែលពុំទាន់បានទទួល**តាវកាលិក** (អត្ថប្រយោជន៍) ដែលមានដូចជា៖

- **-តាវកាលិកព្យាបាល** (សោហ៊ុយសម្រាប់ការព្យាបាលដែលសាមីជនរងគ្រោះ ឬអ្នកតំណាងបានចំណាយជាមុន)
- **-តាវកាលិកថែទាំ** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកថែទាំជនរងគ្រោះក្នុងរយៈពេលសម្រាកនៅមន្ទីរពេទ្យ)
- **-តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យជនរងគ្រោះដែលអាក់ខានធ្វើការងារ ចាប់ពី ២ ថ្ងៃឡើងទៅ)
- **-តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យជនរងគ្រោះដែលខូចខាត ឬបាត់បង់ផ្នែកណាមួយនៃកាយសម្បទាជាអចិន្ត្រៃយ៍)
- **-តាវកាលិកឧត្តរជីវី** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកនៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះថ្នាក់ការងារបណ្តាលឲ្យបាត់បង់ជីវិត)
- **-វិភាជន៍បូជាសព** (ប្រាក់សម្រាប់ផ្តល់ឲ្យអ្នកដែលបានចំណាយសម្រាប់បូជាសព)
- **-តាវកាលិកអ្នកចាំថែរក្សា** (ប្រាក់បំណាច់សម្រាប់ផ្តល់ឲ្យអ្នកមើលថែជនរងគ្រោះបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដែលតម្រូវឲ្យមានអ្នកចាំមើលថែជាប្រចាំ)

បេឡាជាតិរបបសន្តិសុខសង្គមស្នើសុំលោក/លោកស្រី ជាម្ចាស់ ឬនាយក ឬតំណាងនៃសហគ្រាសគ្រឹះស្ថានជូនដំណឹងដល់កម្មករនិយោជិតរបស់ខ្លួនដែលបានទទួលរងគ្រោះថ្នាក់ការងារ និងសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់ដែលពុំទាន់បានធ្វើការទាមទារតាវកាលិកណាមួយដូចបានជម្រាបជូនខាងលើនេះ មកបំពេញសំណុំបែបបទទាមទារតាវកាលិកនៅបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានរួសរាន់។

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថាលោក/លោកស្រី និងបងប្អូនកម្មករនិយោជិតជាសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់នឹងសហការ អនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៥

នាយកបេឡាជាតិរបបសន្តិសុខសង្គម

អ៊ុក-សមវិទ្យា

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ . ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ . ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ . ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ: ៤៨៧៤ សក

ភ្នំពេញ,ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

កម្មវត្ថុ ៖ ករណីស្នើសុំការប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋាន រោងចក្រប្រមូលផ្តុំអ្នកបើកបរ។

យោង ៖ លិខិតលេខ ២១៦២ ក.ប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបើកបររថយន្តដឹកកម្មករនិយោជិតនៅតាមរោងចក្រអាចទទួលបណ្ណបើកបរបានស្របតាមច្បាប់កំណត់ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមឯកភាពតាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំប្រឡង និងផ្តល់បណ្ណបើកបរជូនអ្នកបើកបរដឹកកម្មករនិយោជិត នៅតាមមូលដ្ឋានរោងចក្រប្រមូលផ្តុំ ដោយអនុវត្តតាមនីតិវិធីនៃការបណ្តុះបណ្តាល ប្រឡង និងផ្តល់បណ្ណបើកបរ ដែលមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត សហការជាមួយក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត(ស.ជ.ក) ក្នុងការអនុវត្តផ្ទាល់នៅតាមមូលដ្ឋានរោងចក្រដែលមានការប្រមូលផ្តុំអ្នកបើកបរច្រើន។

ន័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប តាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អាន អំពីខ្ញុំ។

រដ្ឋមន្ត្រី

**កន្លែងទទួល ៖**

- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
«ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

# បន្លែ ផ្លែឈើ ៧យ៉ាង ល្អចំពោះសុខភាព

បន្លែ ផ្លែឈើមួយចំនួន ផ្តល់គុណប្រយោជន៍ដល់សុខភាពបំផុត អាចធ្វើឱ្យរាងកាយរឹងមាំ សុខភាពល្អ ក្មេងជាងវ័យ ថែមទាំងអាចជួយសម្រកទម្ងន់បានផងដែរ...។

**-ផ្លែព្រុន** (Prunes ):

ជាប្រភេទរបស់ប៉ូតាសស្យូម ជាតិដែក និងជាតិសរសៃ ដែលសំខាន់ផ្លែព្រុន ជួយធ្វើឱ្យស្បែកមានឈាមក្រហមព្រើងៗ ចំពោះស្ត្រីឆ្លងចូលវ័យ ២៥ឆ្នាំ រាងកាយចាប់ផ្តើមទ្រុឌទ្រោម ខ្លាញចាប់ផ្តើមផ្តុំ តាមផ្នែកផ្សេងច្រើនលើផ្ទៃមុខ ធ្វើឱ្យជាំខ្មៅ តែអាចទទួលទានផ្លែព្រុនស្រស់ៗ ព្រោះមានវីតាមីន C ជួយក្នុងការស្រូបជាតុផ្សេងៗ ចូលទៅក្នុងរាងកាយ ធ្វើឱ្យសុខភាពល្អ។

**-សណ្តែក** :

ស្ត្រីគ្រប់គ្នាចង់បានរូបរាងស្អាតស្រលនមិនមានខ្លាញផ្តុំ អាទទួលទានសណ្តែកព្រោះជាអាហារ សម្បូរទៅដោយប្រតេអ៊ីនជាតិដែក វីតាមីន B ពេលដែលអ្នកពិសាអាហារមានជាតិសរសៃប្រភេទរលាយក្នុងទឹក ( សណ្តែកមានច្រើន ) ជាតិសរសៃ នឹងគ្របស្បែក្រពះ ធ្វើឱ្យមានអារម្មណ៍ឆ្អែតលឿន និងឆ្អែតបានយូរការចង់ពិសាអាហារថយចុះ មានប្រយោជន៍សម្រាប់ស្ត្រី ដែលត្រូវសម្រកទម្ងន់បាន។

**-ប្រូកខូលី** :

ជាប្រភពសេលេនីញ៉ូម តាមធម្មជាតិ ជួយបង្កើនភាពយឺតស្បែក ទើបធ្វើឱ្យស្បែកមើលទៅក្មេង ជាងវ័យមានសាច់មានឈាមដូចស្ត្រីក្រមុំ ថែមទាំងជួយបន្ថយស្នាមជ្រីញជ្រួញយារស្តាក់ទៀតផង។

**-ចេកពងមាន់** :

ចេកគ្រប់ប្រភេទល្អចំពោះសុខភាព តែចេកពងមាន់ ល្អជាពិសេសក្នុងរឿងនៃសារធាតុប្រឆាំងរ៉ាឌីកាល់សេរី ពិសេសគឺបេតា-ខារ៉ូទីន។ តាមធម្មជាតិពេលយើងចូលដល់អាយុ២២ឆ្នាំ ហើយភាពរីកលូតលាស់របស់រាងកាយចាប់ផ្តើមឈប់ ការចុះខ្សោយផ្នែកផ្សេងៗ របស់រាងកាយយឺតឡើង ដូច្នេះត្រូវទទួលទានចេកពងមាន់ ១ចំណិត មានសារធាតុបេតា-ខារ៉ូទីន ដល់៤៩២មីល្លីក្រាម។

**-ត្របែក** :

ត្របែក ១ចំណិត មានវីតាមីន C ខ្ពស់ដល់១៨០មីល្លីក្រាម។ វីតាមីនC មានតួនាទីក្នុងការបង្កើត ខូលឡាចេន ធ្វើឱ្យសម្រស់លើផ្ទៃមុខតឹងណែន មិចចាស់មុនវ័យ។ វីតាមីនC ជាសារធាតុប្រឆាំងរ៉ាឌីកាល់សេរី ដែលសារធាតុរ៉ាឌីសេរីនេះ ធ្វើឱ្យខូលឡាចេន និងអ៊ីឡាស្ទីន មានភាពចុះខ្សោយ ស្បែកស្ងួតយារ កើតស្នាមជ្រីវជ្រួញ។ វីតាមីន C មានភាពសំខាន់ចំពោះការបង្កើត និងបំប៉នកោសិកា ដូច្នេះសាកល្បងងាកមកទទួលលទាត្របែកជាប្រចាំ។

**- ផ្លែប៉ោម** :

មានសារជាតុសំខាន់ គឺបេតាខារ៉ូទីន វីតាមីន C និងកាកសរសៃប្រភេទរលាយទឹកដែលឈ្មោះផេកទីន មានគុណសម្បត្តិជួយបន្ថយការពិសារអាហារ សម្រកទម្ងន់ និងបន្ថយកូឡេស្តេរ៉ុល។ ប្រសិនអ្នកឃ្លានខ្លាំង តែមិនទាន់ ដល់ពេលអាហារអាចពិសាផ្លែប៉ោម ១ផ្លែ វាជួយបន្ថយភាពឃ្លានបាន ព្រោះផ្លែប៉ោម មានម្សៅ និងស្ករ ក្នុងលក្ខណៈនៃស្ករម៉ូលេគុលទោល ដល់៧៥% ធ្វើឱ្យរាងកាយអាចស្រូបស្ករប្រភេទនេះបានរហ័ស និងយកទៅប្រើ ជាប្រយោជន៍បានក្នុងពេលមិនលើស១០នាទី។ ដូច្នេះចំណង់អាហារថយចុះ អាចទទួលទាន ២-៣ផ្លែ ក្នុងមួយថ្ងៃ។

**-ត្រួច** :

ជាប្រភេទវីតាមីន ជាតិរ៉ែ ចនិងកាកសរសៃធម្មជាតិ ការទទួលទាក្រូច ដោយមិនខ្ចាក់កាក ជួយគ្រប់គ្រងទម្ងន់បានមួយវិធីទៀត ព្រោះមានអារម្មណ៍ឆ្អែតលឿន ជាប្រយោជន៍សម្រាប់អ្នកត្រូវការសម្រកទម្ងន់៕

អត្ថបទនេះដល់ស្រង់ពីទស្សនាវត្តីអង្គរធំ



# ទស្សនៈគួរពិចារណា


ជោគជ័យគឺសម្រាប់តែ
អ្នកហ៊ានចាប់ផ្ដើមប៉ុណ្ណោះ
SATHAPANA LIMITED


ជ័យជំនះធំបំផុត
ដែលអ្នកត្រូវមាន
គឺការយកឈ្នះខ្លួនឯង
RHYTHM
JAPAN


វិទ្យុ Cool FM 100.7
ពេលកូនមានកំហុស
ម៉ែទូន្មានចាស្តី
កូនឈឺត្រឹមមួយរាត្រី
ប៉ុន្តែទ្រូងម្ដាយថ្ងៃឈឺជាងកូនគ្មានអ្វីថ្លែង
www.cool1007.com


វិទ្យុ Cool FM 100.7
មនុស្សស្អាត ព្រោះវិជ្ជា
ស្រីស្រស់ស្អាតសោភា ព្រោះមារយាទ
www.cool1007.com


វិទ្យុ Cool FM 100.7
របស់មាន តម្លៃ ប៉ុណ្ណាក៏ដោយ
បើឱ្យមនុស្សគ្មានតម្លៃមើល
ក៏មើលមិនឃើញពីតម្លៃរបស់វាដែរ!
www.jobs.cool1007.com
www.cool1007.com



# ទូរស័ព្ទ ១២៨៦
# ក្រុមប្រចាំការ Hotline 24 ម៉ោង

ចាប់តាំងពីការដាក់ឲ្យដំណើរការ របបធានារ៉ាប់រងហានិភ័យការងារ (គ្រោះថ្នាក់ការងារ)រហូតមកដល់បច្ចុប្បន្ន មានរយៈពេលជិត ៧ឆ្នាំ ហើយដោយទទួលបានជោគជ័យគួរជាទីមោទនៈ។ ទន្ទឹមនឹងភាពជោគជ័យនេះដែរ បេឡាជាតិរបបសន្តិសុខសង្គម បាននឹងកំពុងរៀបចំជាបណ្តើរៗ នូវការដាក់ឲ្យដំណើរការរបបធានារ៉ាប់រងសុខភាព ដែលជាជំហានទី ២ របស់ខ្លួន ដែលគម្រោងនឹងដាក់ឲ្យដំណើរការនៅពាក់កណ្តាលឆ្នាំ២០១៩នេះ និងដើម្បីរួមចំណែក ក្នុងការជំរុញឲ្យរបបធានារ៉ាប់រងសុខភាព ទទួលបានជោគជ័យ ដូចរបបធានារ៉ាប់រងហានិភ័យការងារ។ ក្រុមការងារ HOTLINE ដែលជាផ្នែកមួយដ៏សំខាន់ នៃ ប.ស.ស ប្រចាំការ ២៤ម៉ោង ទំនាក់ទំនងមកកាន់លេខ ១២៨៦ នៅពេលបងប្អូនកម្មករនិយោជិតទទួលរងហានិភ័យការងារ (គ្រោះថ្នាក់ការងារ ) បញ្ហាគ្រោះថ្នាក់ការងារ នៅកន្លែងធ្វើការ ពេលកំពុងធ្វើដំណើរទៅ និងត្រឡប់មកពីកន្លែងធ្វើការ និងជម្ងឺវិជ្ជាជីវៈ។ ទន្ទឹមគ្នានេះ ក្រុមការងារទទួលភារកិច្ចសម្របសម្រួលការងារបានជាច្រើនករណី ទាក់ទងនឹងផ្នែកបម្រើសេវានេះ ក្នុងនោះរួមមានករណីសន្លប់ គ្រោះថ្នាក់ចរាចរណ៍ និងករណីផ្សេងៗទៀត ដែលចាំបាច់តម្រូវឱ្យក្រុមការងារមានការសម្របសម្រួលជាបន្ទាន់ដោយធ្វើការផ្តល់ព័ត៌មានដល់មន្ទីរពេទ្យ និងការិយាល័យជំនាញពាក់ព័ន្ធ ដើម្បីបម្រើសេវាសាធារណៈជូនដល់ជនរងគ្រោះ ឱ្យបានទាន់ពេលវេលា។

ជាក់ស្តែងក្នុងឆ្នាំ២០១៥ ក្រុមការងារ HOT LINE បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម និងបានទទួល និងផ្តល់ព័ត៌មានសង្គ្រោះបន្ទាន់សម្របសម្រួលការងារ និងដោះស្រាយបញ្ហាផ្សេងៗបានជាច្រើនករណី ជូនដល់បងប្អូនកម្មករនិយោជិតទាំងនៅកំពុងធ្វើការងារក្តី ពេលធ្វើដំណើរទៅមកពីផ្ទះទៅកន្លែងធ្វើការ និងជម្ងឺវិជ្ជាជីវៈ បានជាច្រើនលើក និងជាច្រើនករណីជាបន្តបន្ទាប់។

ទន្ទឹមនឹងទទួលបានលទ្ធផលជាផ្លែផ្កាក្តី ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរ ដែលតម្រូវឲ្យក្រុមការងារ HOTLINE នៅតែខិតខំប្រឹងប្រែងដោះស្រាយ រាល់ការប្រឈមនោះឲ្យមានភាពរលូន និងរហ័សទាន់ ពេលវេលា ដើម្បីបម្រើសេវាសាធារណៈ ជូនដល់សមាជិក នៃបេឡាជាតិរបបសន្តិសុខសង្គម ឲ្យបានល្អបន្ថែមទៀត៕



សកម្មភាពទំនាក់ទំនងការងារ របស់អតិថិជនជាមួយក្រុមការងារ HotLine

# សាខា ប.ស.ស តាមបណ្តារាជធានី-ខេត្ត

### ទីស្នាក់ការកណ្តាល ប.ស.ស រាជធានីភ្នំពេញ
អាសយដ្ឋានៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទៈ ០២៣ ៨៨២ ៨៣៤, ០២៣ ៩៩៨ ៩១៧
០២៣ ៩៩៨ ៩១៨, ០២៣ ៩៩៨ ៩១៩
ទូរសារៈ ០២៣ ៨៨២ ៦២៣
គេហទំព័រៈ www.nssf.gov.kh

### សាខា ប.ស.ស ខេត្តសៀមរាប
អាសយដ្ឋានៈ ផ្ទះលេខP១០ ភូមិត្រពាំងសេះ ឃុំគោកចក
ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទដៃៈ ០១២ ៥៣៤ ៣៩៥, ០៧៧ ៦៦៣ ២១៧
ទូរស័ព្ទៈ ០៦៣ ៩៦៥ ៩៣៤
គេហទំព័រៈ www.nssf.gov.kh
E-mail: pang_sokchea@yahoo.com

### សាខា ប.ស.ស ខេត្តកណ្តាល
អាសយដ្ឋានៈ ផ្ទះលេខ០១ ផ្លូវលេខ២០២ ភូមិដើមមៀន
សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល
ភូមិក្នុង ផ្លូវផ្សារព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល
ខេត្តកណ្តាល
ទូរស័ព្ទៈ ០២៤ ៦៤០ ១៦៧៦, ០៧៧ ៩៦៣ ០៧៨
E-mail: kandal_@nssf.gov.kh

### សាខា ប.ស.ស ខេត្តបន្ទាយមានជ័យ
អាសយដ្ឋានៈ ភូមិគីឡូម៉ែតលេខ៤ សង្កាត់ផ្សារកណ្តាល
ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
ភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសេរីសោភ័ណ
ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទៈ ០៥៤ ៧១១ ៩៩១, ០៧៧ ៦៦៣ ២១៨
E-mail: nssf_bmc@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ស្ពឺ
អាសយដ្ឋានៈ ផ្ទះលេខ៣៦A ភូមិស្វាយជ្រុំ ឃុំបែកចាន
ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទៈ ០២៤ ៦៨៨ ០០៩៧, ០៧៧ ៥៧០ ៩០៧
E-mail: nssf_ksp@nssf.gov.kh
movratha@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ចាម
អាសយដ្ឋានៈ ផ្លូវជាតិលេខ៧ សង្កាត់វាលវង់
ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ទូរស័ព្ទៈ ០៤២ ៦៥២ ១៩៩៩, ០៧៧ ៩៩០ ០៤៨
E-mail: nssf_kpc@nssf.gov.kh
say.sothon@nssf.gov.kh

### សាខា ប.ស.ស ខេត្តព្រះសីហនុ
អាសយដ្ឋានៈ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទៈ ០៣៤ ៩៣៤ ៦០៦, ០៧៧ ៦៦៣ ២១៥
E-mail: nssf_shv@nssf.gov.kh
tong_samnieng@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពង់ធំ
អាសយដ្ឋានៈ ភូមិទី៧, សង្កាត់កំពង់ធំ, ក្រុងស្ទឹងសែន
ខេត្តកំពង់ធំ
ទូរស័ព្ទៈ ០៦២ ២១០ ៩៦៣, ០៩២ ៧៤៧ ០៩៩
E-mail: kp_thom@nssf.gov.kh
ly_sokha2007@yahoo.com

### សាខា ប.ស.ស ខេត្តស្វាយរៀង
អាសយដ្ឋានៈ ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត
ក្រុងបាវិត ខេត្តស្វាយរៀង
ទូរស័ព្ទៈ ០៤៤ ៧១៥ ៨៣១, ០៧៧ ៦៦៣ ២១៤
E-mail: pek.samol@nssf.gov.kh

### សាខា ប.ស.ស ខេត្តព្រៃវែង
អាសយដ្ឋានៈ ផ្ទះលេខ១០៧ ភូមិលេខ៣ សង្កាត់កំពង់លាវ
ក្រុងព្រៃវែង ខេត្តព្រៃវែង
ទូរស័ព្ទៈ ០៩២ ៧០៨ ៨០៣, ០១២ ៥៨៨ ៨០៥
E-mail: preyveng@nssf.gov.kh
reythearith@yahoo.com

### សាខា ប.ស.ស ខេត្តកំពង់ឆ្នាំង
អាសយដ្ឋានៈ ផ្ទះលេខC495 ភូមិម៉ុងបារាំង សង្កាត់ប្អេរ
ក្រុមទី១៨ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទៈ ០២៦ ៧៧៥ ៥៦៦, ០៧៧ ៦៦៣ ២១៦
E-mail: nssf_kcn@nssf.gov.kh

### សាខា ប.ស.ស ខេត្តក្រចេះ
អាសយដ្ឋានៈ ភូមិរកាកណ្តាលទី១ សង្កាត់រកាកណ្តាល
ក្រុងក្រចេះ ខេត្តក្រចេះ
ទូរស័ព្ទៈ ០៩២ ៨៧៣ ០៥១, ០៧៧ ៥៧០ ៩០៩
E-mail: kratie@nssf.gov.kh
soksay.he@nssf.gov.kh

### សាខា ប.ស.ស ខេត្តកំពត

អាសយដ្ឋាន: ភូមិ១ឧសភា ឃុំកំពង់កណ្តាល
ស្រុកកំពង់បាយ ក្រុងកំពត ខេត្តកំពត

ទូរស័ព្ទ: ០៣៣ ៩៣២ ១៣៣, ០១២ ៦២៣ ៣២២

E-mail: kompot@nssf.gov.kh
phakchetra@gmial.com

### សាខា ប.ស.ស ខេត្តពោធិ៍សាត់

អាសយដ្ឋាន: ផ្ទះលេខ០០៧ ភូមិរ៉ា សង្កាត់ផ្ទះព្រៃ
ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

ទូរស័ព្ទ: ០៥២ ៩៥១ ១២៣, ០៩២ ៧០៧ ៣៨៥

E-mail: nssf_ps@nssf.gov.kh

### សាខា ប.ស.ស ខេត្តបាត់ដំបង

អាសយដ្ឋាន: ផ្ទះលេខP៩ បូរីពាណិជ្ជកម្មបាត់ដំបង
ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ទូរស័ព្ទ: ០៥៣ ៩៥៣ ៣៣៦, ០៩៧ ៩៩៧ ២៨២៩

E-mail: battambang@nssf.gov.kh

### សាខា ប.ស.ស ខេត្តកោះកុង

អាសយដ្ឋាន: ផ្ទះលេខ២៦ ក្រុម២ ភូមិ៣ សង្កាត់ដងទង់
ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

ទូរស័ព្ទ: ០៣៥ ៩៣៦ ៤៣៦, ០៩៧ ៩៧៣ ៩០០៦

E-mail: kongkea.nssf.kk@gmail.com

### សាខា ប.ស.ស ខេត្តប៉ៃលិន

អាសយដ្ឋាន: ភូមិវត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន
ខេត្តប៉ៃលិន

ទូរស័ព្ទ: ០៥៥ ៩៥៦ ៦៦៧, ០៨៦ ៨៩៣ ៧៧៧

E-mail: somit.ream@nssf.gov.kh

### សាខា ប.ស.ស ខេត្តតាកែវ

អាសយដ្ឋាន: ផ្លូវលេខ១០ ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ
ខេត្តតាកែវ

ទូរស័ព្ទ: ០៣២ ២១០ ៦៦៦, ០១២ ៦៣៦ ៩៣៩

E-mail: takeo_@nssf.gov.kh

### សាខា ប.ស.ស ខណ្ឌដង្កោ

អាសយដ្ឋាន: ផ្ទះលេខ១២A ផ្លូវវេងស្រេង សង្កាត់ចោមចៅ
ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
(ទល់មុខផែរស្លូតស្វូរង្ហូន)

ទូរស័ព្ទ: ០១២ ៦៩៥ ៥៥០, ០២៣ ៩៩៥ ៤៨៤

E-mail: lpl@nssf.gov.kh

### សាខា ប.ស.ស ខេត្តរតនគិរី

អាសយដ្ឋាន: ភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង
ខេត្តរតនគិរី

ទូរស័ព្ទ: ០៩៧ ៩៦៦ ៧៦៦៦, ០១១ ៩៥១ ៧៧៧
០៧៥ ៩៧៤ ១៨៤

E-mail: sam_ath@nssf.gov.kh

### សាខា ប.ស.ស ខេត្តមណ្ឌលគិរី

អាសយដ្ឋាន: ភូមិចំបក់ សង្កាត់ស្ពានមានជ័យ
ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

ទូរស័ព្ទ: ០១២ ២០៥ ៧៥៦, ០៨៨ ៨២០ ៥៧៥៦

E-mail: kosol_vicheth@yahoo.com

### សាខា ប.ស.ស ខេត្តឧត្តរមានជ័យ

អាសយដ្ឋាន: ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង
ខេត្តឧត្តរមានជ័យ

ទូរស័ព្ទ: ០៩៧ ៥២៣ ៤៦៦៦ ០៨៥ ៣១១ ៣០០

E-mail: simao2013@gmial.com

### សាខា ប.ស.ស ខេត្តស្ទឹងត្រែង

អាសយដ្ឋាន: ភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង
ខេត្តស្ទឹងត្រែង

ទូរស័ព្ទ: ០១២ ៤០៥ ៤៥១

E-mail: nganrathana@gmial.com

### សាខា ប.ស.ស ខេត្តព្រះវិហារ

អាសយដ្ឋាន: ភូមិកណ្តាល ឃុំកំពង់ប្រណាក
ក្រុងព្រះវិហារ ខេត្តព្រះវិហារ

ទូរស័ព្ទ: ០៩៧ ៣៦៦ ៦០៦០, ០១២ ២៥៩ ២៥៨

E-mail: nssf_pvh@nssf.gov.kh

### សាខា ប.ស.ស ខណ្ឌឫស្សីកែវ

អាសយដ្ឋាន: ផ្ទះលេខ៥០ EoE1 ផ្លូវលេខ៣ ក្រុមទី៤
ភូមិបឹងឈូក សង្កាត់គីឡូម៉ែត៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ៦៦៣ ៣០៣០, ០៩២ ៤៨៦ ២៥៦

E-mail: vannaknssf@gmial.com

# បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ០១ | មន្ទីរពេទ្យកាលម៉ែត | ១១៩ | ០២៣ ៤២៦ ៩៤៨<br>០២៣ ៧២៤ ៨៩១ | ០៩៧ ៦៨៧ ២៤២៦<br>០៧៧ ៩៧៨ ៤៧៤ | |
| ០២ | មន្ទីរពេទ្យព្រះកុសុមៈ | ១១៩ | ០១២ ៦៥៧ ៦៥៣<br>០១៦ ៩០៩ ៧៧៤ | ០៩៧ ៦៨៧ ២៤២៩<br>០៩២ ៨២០ ២៥៩<br>០១២ ៦៦៩ ៩៤៦ | |
| ០៣ | មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ១១៩<br>០៧៨ ៩៩៧ ៩៧៨ | ០២៣ ២១៧ ៧៦៤<br>០១២ ៨៥៨ ១៨៤ | ០៩៧ ៦៨៧ ២៤២៧<br>០៩២ ៥៩១ ៣៧៧<br>០១២ ៣០៥ ៣៧១ | |
| ០៤ | មន្ទីរពេទ្យព្រះអង្គឌួង | ០១៦ ៥០៥ ៤៥៣ | ០១១ ៧៥៥ ១១៩<br>០៧៧ ៥៥០ ០១៧ | | |
| ០៥ | មណ្ឌលសុខភាពទួលគោល | ១១៩<br>០១២ ៥១៩ ៩១៦ | ០១១ ៨៣៣ ៣៣៩<br>០២៣ ៣៥១ ១៩៨ | | |
| ០៦ | មន្ទីរពេទ្យបង្អែកសម្តេចឪ | ១១៩<br>០៧៨ ៣៩៨ ៦៦៧ | ០១២ ៥៣២ ៨០៣<br>០១២ ៨៦៤ ៥០៩ | | ភ្នំពេញ |
| ០៧ | មណ្ឌលសុខភាពទឹកថ្លា | ១១៩<br>០៧៧ ៧៩៧ ៩៦៧ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៨ | មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង | ១១៩<br>០១២ ៨៥៣ ០១៣ | ០១៧ ៧២២ ០៦៥<br>០២៣ ៣៥១ ១៩៨ | | |
| ០៩ | មណ្ឌលសុខភាពគោករកា | | ០១៧ ៧៧៥ ៤៧២ | | |
| ១០ | មណ្ឌលសុខភាពស្ទឹងមានជ័យ | | ០១២ ៩៧១ ៤៧៦ | ០៧៧ ៦៣៦ ៣៦០ | |
| ១១ | មន្ទីរពហុព្យាបាល និងសម្ភព សុខ លាភ មេត្រី | ០១១ ៣៩៨ ៨៨៨ | ០២៣ ៦៦៦ ៦២៣៧<br>០១២ ៦០៣ ១៣១ | | |
| ១២ | មន្ទីរសម្រាកព្យាបាលមូលមិត្ត | ០៩៧ ៧៦៣ ៩០០៣ | ០១២ ៤៤៩ ៦០៨ | | |
| ១៣ | មន្ទីរពេទ្យជ័យជំនះ | ០១៥ ៥១៩ ១១៩ | ០១២ ៩១២ ៥២៣<br>០៧៧ ៩៣៣ ៤៥៩ | ០៩៧ ៦៨៧ ២៤២៨ | |
| ១៤ | មណ្ឌលសុខភាពបែកចាន | ០១២ ៥៧១ ៦៦៦<br>០១២ ១៧៥ ៨២៨៥<br>០៩៧ ៤៩៩ ៨៩៣៦ | ០១២ ៨៩៤ ២៦០ | ០៩៧ ២៩៩ ៦៦៦៩<br>០៩៦ ៣៦៩ ៥៩១២ | |
| ១៥ | មន្ទីរពេទ្យបង្អែកអង្គស្នួល | ០១២ ៥៨១ ៦៣៩ | ០១២ ៨៩៤ ២៦០<br>០៦៩ ៧០៥ ៧៥៧ | | |
| ១៦ | មន្ទីរពេទ្យបង្អែកកោះធំ | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨<br>០១៦ ៤៧១ ៨៨៧ | | កណ្ដាល |
| ១៧ | មន្ទីរពេទ្យបង្អែកស្រុកស្អាង | ១១៩<br>០១៧ ៧២២ ០៦៥ | ០២៣ ៣៥១ ១៩៨ | | |
| ១៨ | មណ្ឌលសុខភាពព្រែកអញ្ចាញ | | ០១៧ ៥៥២ ៣២៣<br>០១២ ៨៤០ ៥២០ | | |
| ១៩ | មណ្ឌលសុខភាពវិហារសួគ៌ | ០៧៧ ៩២៦ ៦៩២ | ០១២ ៨៣២ ៣៤៣<br>០១២ ៤៩៥ ៩៨៣ | | |
| ២០ | មណ្ឌលសុខភាពសំរោងធំ | ០៩៧ ៧៩៣ ៩៩៧៤ | | | |
| ២១ | មន្ទីរពេទ្យខ្សាច់កណ្ដាល | ០៩៧ ៥៤០ ៤០០៦ | ០១២ ៤៤៦ ៥៩២<br>០១២ ៤៣៤ ៥៤៦ | | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ូយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ២២ | មន្ទីរពេទ្យបង្អែកប៊ុន រ៉ានី ហ៊ុនសែន រការកោង | ០១៧ ៥៥២ ៣២៣ | ០៩៧ ៩៥៣ ៩៥២៥<br>០១៧ ៥៥២ ៣២៣ | ០៩២ ៤០៧ ៨៦៨ | |
| ២៣ | មន្ទីរពេទ្យបង្អែកកំពង់ស្ពឺ | ០១៦ ៦៩៦ ៤៨០ | ០២៥ ៩៨៧ ៣១៣<br>០១៦ ៤៧១ ៨៨៧ | ០៩៧ ៧៨៣ ៩៣៩១ | កំពង់ស្ពឺ |
| ២៤ | មន្ទីរពេទ្យបង្អែកឧដុង្គ | ០៣៨ ៨៩១ ៩១៣<br>០១២ ៩៣៨ ៩២៥ | ០១២ ៩៧៨ ៩២៥<br>០១២ ៩១០ ០៦២ | | |
| ២៥ | មន្ទីរពេទ្យបង្អែកស្វាយរៀង | ០៤៤ ៩៤៥ ១១១ | ០១២ ៩៥៣ ៩៧៥ | ០៩៧ ៧៨៣ ៨៧៦៥ | ស្វាយរៀង |
| ២៦ | មន្ទីរពេទ្យបង្អែកជីភូ | ០១១ ៣៩៤ ១៧៨ | ០១២ ៨០៥ ២៣៦<br>០១២ ៧៦១ ០៨៩ | | |
| ២៧ | មន្ទីរពេទ្យបង្អែកកំពង់ឆ្នាំង | ០២៦ ៩៨៨ ១១១ | ០១៥ ២៥០ ១១១<br>០១២ ៧០២ ២៥១ | | កំពង់ឆ្នាំង |
| ២៨ | មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច | ០៨៥ ៥៨៧ ៧៥៧ | ០៨៥ ៥៨៧ ៧៩០<br>០១២ ៤៥៧ ៣០៨ | ០៨៨ ៩៧២ ១០១៦ | |
| ២៩ | មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ | ០១៦ ៦៨៦ ៨៤៣<br>០៨៨ ៨៦០ ០០៣៩ | ០១២ ៧១២ ៦៤៦<br>០១៦ ៧១២ ៦៤៦ | ០៨៨ ៩៧២ ១០១៤ | ព្រះសីហនុ |
| ៣០ | មន្ទីរពេទ្យ CT (ខេត្តព្រះសីហនុ) | ០៨៩ ៨៨៦ ៦៦៦<br>០៨៥ ៨៨៦ ៦៦៦ | ០៨១ ៨៨៦ ៦៦៦ | | |
| ៣១ | មណ្ឌលសុខភាពវាលរេញ | ០១៦ ៤៥២ ៧៦១ | ០១៦ ២៦៩ ៧៤៤<br>០១២ ៩៨៣ ៦១២ | | |
| ៣២ | មណ្ឌលសុខភាពអណ្ដូងថ្ម | | ០១៥ ៤៥៤ ៥៦២ | | |
| ៣៣ | មណ្ឌលសុខភាពរាម | | ០១៦ ៦២៥ ០១១ | | |
| ៣៤ | មន្ទីរពេទ្យបង្អែកសៀមរាប | ០១២ ៦៣០ ២៧៦ | ០១២ ៦៦៦ ៤៨១ | ០៧៧ ៦៦៣ ២១៧<br>០១២ ៣៨២ ៣០២ | សៀមរាប |
| ៣៥ | មណ្ឌលសុខភាពពួក | ០៨៨ ៨៣៤ ៦២៥៧ | ០៩២ ៩១០ ០២៧ | | |
| ៣៦ | មន្ទីរពេទ្យបង្អែកប៉ោយប៉ែត | ០១២ ៨៣៣ ១៥៩ | ០៨៩ ៨៣៧ ៦៣៧<br>០១២ ៨៣៣ ១៥៩<br>០៩៧ ៧២៦ ៦៤៣០ | ០៦៩ ២៥២ ៧៩៧ | បន្ទាយមានជ័យ |
| ៣៧ | មន្ទីរពេទ្យបង្អែកខេត្តមិត្តភាពកម្ពុជា-ជប៉ុនមង្គលបុរី | ០១២ ៩៣២ ៥២១ | ០១២ ៩២៣ ៣៥៤<br>០៩៧ ៧៤០ ៥៤០១ | | |
| ៣៨ | មន្ទីរពេទ្យបង្អែកសិរីសោភ័ណ | ០១២ ៩១០ ៤៦៧ | ០១២ ៨៥៤ ៩៨៣ | | |
| ៣៩ | មន្ទីរពេទ្យបង្អែកស្រុកជើងព្រៃ | ០១២ ៦៦៧ ៤៨៦<br>០៨៨ ៧៧៤ ៤៧៨៨ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៨៧១ ០៤៣ | កំពង់ចាម |
| ៤០ | មន្ទីរពេទ្យបង្អែកស្រុកពញាក្រែក | ០៨៨ ៧៧៤ ៤៧១១ | ០៧៧ ៩៩០ ០៤៨ | ០៩៣ ៦៦៩ ៦៣៧<br>០៧៧ ២៦០៤៦៧ | |
| ៤១ | មន្ទីរពេទ្យបង្អែកស្រុកត្បូងឃ្មុំ | ០៨៨ ៧៧៤ ៤៧០០ | ០៧៧ ៩៩០ ០៤៨ | ០៩៧ ៣៨៦ ៨៤២៣ | |
| ៤២ | មន្ទីរពេទ្យបង្អែកស្រុកមេមត់ | ០៨៨ ៧៧៤ ៤៧២២<br>០១២ ៩៦១ ៣៩៣ | ០៧៧ ៩៩០ ០៤៨ | | |
| ៤៣ | មន្ទីរពេទ្យបង្អែកស្រុកព្រៃឈរ | ០១១ ៣៩៨ ១៣៥<br>០៨៨ ៧៧៤ ៤៧៦៦ | ០៩៧ ៧៣៣ ២២៥៥<br>០៨៥ ៤១៤ ៥៥៦ | ០៧៧ ៩៩០ ០៤៨<br>០១២ ៨២២ ៤១១ | |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានីខេត្ត |
|---|---|---|---|---|---|
| ៤៤ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម | ០១២ ៨២៣ ៧០៩<br>០៩២ ៩៥៧ ៨៧១ | ០៧៧ ៩៩០ ០៤៨ | ០១៧ ៦២៣ ៧៦៧ | កំពង់ចាម |
| ៤៥ | មន្ទីរពេទ្យបង្អែកព្រៃកក់(ស្ទឹងត្រង់) | ០១២ ៤៩៥ ១៤៨<br>០៩២ ៣២២ ៤១៣ | ០១២ ៤៩៥ ១៤៨<br>០១១ ២៩៤ ៥៣២ | | |
| ៤៦ | មន្ទីរពេទ្យបង្អែកខេត្តក្រចេះ | ០៧២ ២១០ ៣៩១<br>០១២ ៨២២ ៣៩១ | ០១២ ៩៣១ ៨៦៨ | ០៩៧ ៧៩៧ ៨៩៩៩<br>០៩៧ ៩៨៩ ៦៦៩១ | ក្រចេះ |
| ៤៧ | មន្ទីរពេទ្យបង្អែកស្រុកឆ្លូង | ០១២ ៥០២ ៩០៣<br>០១៧ ៩០៩ ៦៥៣ | ០១២ ៣៦៧ ៧០២ | | |
| ៤៨ | មន្ទីរពេទ្យបង្អែកស្រុកស្នួល | ០៩៧ ៧៥២ ៧៩៩៦ | ០៩៧ ៨០០ ៨៥៥៥<br>០៩៧ ៦៥៩ ៧២៩៩ | | |
| ៤៩ | មន្ទីរពេទ្យបង្អែកអ្នកលឿង | ០១២ ៧៧៥ ៣១៩ | ០១២ ៦៦០ ៨១៥ | | ព្រៃវែង |
| ៥០ | មន្ទីរពេទ្យបង្អែកព្រៃវែង | ០៩៧ ៧៨១ ៦៧៣៥<br>០៨៨ ៨៨០ ០០៧៨ | ០៩៧ ៧៩៥ ៧៤៧២<br>០១៦ ៧១២ ៨០៦ | | |
| ៥១ | មន្ទីរពេទ្យបង្អែកពារាំង | ០៩២ ៦៥៣ ៥៩៥<br>០១២ ៦៥៣ ៥៩៥ | ០៩២ ២២៣ ៦១៤<br>០៤៣ ៦៩០ ០៩០៥ | | |
| ៥២ | មណ្ឌលសុខភាពក្អៀងរាយ | ០១២ ៦៥៨ ៣០៣ | ០១២ ៤៣៩ ៣៤៣<br>០១២ ២៩៧ ៤៩១ | | |
| ៥៣ | មន្ទីរពេទ្យបង្អែកស្រុកចំចាយមារ | ០១២ ៦៩៣ ៩៤០ | ០១២ ៥៨៨ ៤៩៥<br>០៩៥ ៨៨១ ៧០៧ | | |
| ៥៤ | មន្ទីរពេទ្យខេត្តតាកែវ | ០១២ ៩៣៥ ៨១៤ | ០១១ ៩០៥ ០១៩<br>០១២ ១៧២ ៨៣៤៨ | | តាកែវ |
| ៥៥ | មន្ទីរពេទ្យបង្អែកបាទី | ០១២ ៧២៤ ០៩៣<br>០៩៧ ៦៤៧ ៤៣០៣ | ០៣២ ៦៩០ ១៩៣៩ | | |
| ៥៦ | មណ្ឌលសុខភាពត្រាំខ្នារ | ០៨១ ៤៤៤ ១៧៤<br>០១២ ៤២៤ ០៦៣ | ០៩៧ ៩៥៩ ៤៦៥៣<br>០១២ ៧២៤ ០៩៣ | ០១២ ៩៤៤ ១៧៤ | |
| ៥៧ | មន្ទីរពេទ្យភ្នែកតាកែវ | | ០១៦ ៩០៤ ៨៩០ | | |
| ៥៨ | មន្ទីរពេទ្យខេត្តកែប | ០១២ ៩១២ ៣២០ | ០១២ ៨២៥ ២៧៧<br>០១២ ៤៥៦ ២៤៧ | | កែប |
| ៥៩ | មន្ទីរពេទ្យបង្អែកខេត្តកំពត | ០១២ ២៩៧ ២៦៨ | ០១២ ៣១៦ ១៣៥<br>០១២ ៩៥៥ ៩៨៦ | | កំពត |
| ៦០ | មន្ទីរពេទ្យបង្អែកកំពង់ត្រាច | ០១២ ៧៣៣ ៤៦៨ | ០៩២ ៣៨៣ ៦៣២<br>០៨៨ ៨៧៣ ២៤៦៨ | | |
| ៦១ | មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ១៣៥៣<br>/០០១០ | ០១២ ៨២៨ ៤៦៦ | | ពោធិ៍សាត់ |
| ៦២ | មណ្ឌលសុខភាពឈើតុំ | ០៩២ ៣០៧ ២៧៨ | | | |
| ៦៣ | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | ០៩២ ៨១១ ១៦១ | ០៩៧ ១២២ ២៣៤៤ | | |
| ៦៤ | មន្ទីរពេទ្យបង្អែកស្រុកភ្នំក្រវ៉ាញ | ០១២ ៨៥០ ៥៩០ | | | |
| ៦៥ | មន្ទីរពេទ្យបង្អែកស្រែអំបិល | ០១៦ ២២២ ១៨៦ | ០១៦ ៨៧៧ ០០៦ | | កោះកុង |

| ល.រ | ឈ្មោះមន្ទីរពេទ្យ | ឡានសាម៉ុយ | ទូរស័ព្ទទាន់ហេតុការណ៍ | ភ្នាក់ងារ ប.ស.ស | រាជធានី ខេត្ត |
|---|---|---|---|---|---|
| ៦៦ | មន្ទីរពេទ្យបង្អែកខេត្តកោះកុង | ០១៦ ៣០០ ១១៩ | ០១៦ ២០៤ ៨៨៧<br>០៩៧ ៧៩៥ ៨៧៨៨ | | កោះកុង |
| ៦៧ | មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន | | ០៧១ ៩១៤ ៤៤១៨<br>០១៥ ៥៣២ ៣២៣<br>០៩៧ ៧៥៣ ២៣២៣ | | ប៉ៃលិន |
| ៦៨ | មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង | ០១២ ២៦៩ ៣៨៨ | ០១២ ៨៣៣ ២៦១ | | បាត់ដំបង |
| ៦៩ | មណ្ឌលសុខភាពត្រាង | ០៩៥ ២២៨ ៨៩៣<br>០៩៧ ៩១៤ ៥៨៧០ | ០១៧ ២៦៩ ៣៦៣ | | |
| ៧០ | មណ្ឌលសុខភាពស្ដៅ | ០១២ ៥៨១ ៦៥៤<br>០៩២ ២៦៤ ១៦៣ | ០១២ ៦៧០ ៩៩៦ | | |
| ៧១ | មន្ទីរពេទ្យបង្អែកសំពៅលូន | ០១២ ៩៧៤ ២២៣<br>០៨៨ ៩១៨ ១០០៥ | ០១២ ៤៤៨ ១៩៦ | | |
| ៧២ | មន្ទីរពេទ្យបង្អែកថ្មគោល | ០៩២ ៩០៣ ៦៩៤ | ០៩២ ៧៨៦ ៣៥៦ | | |
| ៧៣ | មន្ទីរពេទ្យបារាយណ៍-សន្ទុក | ០១២ ៨៦៧ ៥៧៣ | ០១៧ ៥៥៩ ៣៨៧ | | កំពង់ធំ |
| ៧៤ | មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ | ០១៧ ៣៩៨ ៧៥០<br>០១២ ៩៤៧ ៩៣២ | ០៩២ ៩៥៤ ៣៦៧ | | |
| ៧៥ | មន្ទីរពេទ្យបង្អែកស្ទោង | ០១២ ៧៦៨ ៤៤៣<br>០១២ ៧៩៤ ៣៤៩ | ០៩២ ២៩១ ៩៥៩ | | |
| ៧៦ | មន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែង | ០៩២ ៧៩៩ ៤៦៤<br>០៨៨ ៨៨៤ ៩៤៨៣ | ០៩៧ ៩៧៨ ០៨៧៨<br>០១២ ៩០៨ ៥៩០ | | ស្ទឹងត្រែង |
| ៧៧ | មន្ទីរពេទ្យបង្អែកខេត្តរតនគិរី | ០១៧ ៩៣៦ ៩៤៥<br>០១២ ៨៤០ ៨០៨<br>០១៧ ៣៥៧ ៣២០ | ០១២ ៥០៥ ០០៨<br>០១២ ៥២៨ ០០៨ | | រតនគិរី |
| ៧៨ | មន្ទីរពេទ្យបង្អែកបរកែវ | ០៩៧ ៩៩០ ៩៨៩៩ | ០១១ ៨៣៨ ៣០០<br>០១២ ៥១១ ៣៦៩ | | |
| ៧៩ | មន្ទីរពេទ្យបង្អែកសែនមនោរម្យ | ០៩៧ ៧១២ ១៤៤៥<br>០១២ ៩៦១ ៧៤៤ | ០៩៧ ៤៧៣ ៩៦៨៥<br>០៨៨ ៩៩៨ ៦៥៦៦ | | មណ្ឌលគិរី |
| ៨០ | មណ្ឌលសុខភាពអូររាំង | ០៩៧ ៤៧៨ ៧៧៩៧ | ០១១ ៦០៧ ៧៨៣<br>០៨៨ ៣៣២ ៩១១៨ | | |
| ៨១ | មណ្ឌលសុខភាពកែវសីម៉ា | ០៩៧ ៦៧៨ ៨៥៣៣ | ០១២ ២៦៦ ១៥២<br>០៩៧ ៨៥០ ៤៧៦៥ | | |
| ៨២ | មន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ | ០៩២ ១៤១ ៨៣៥<br>០១២ ៧២៣ ១២១ | ០៧៨ ២២៩ ៧៩៧<br>០៧៨ ៩៧៩ ៧២៩ | | ឧត្តរមានជ័យ |
| ៨៣ | មន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង | ០៧៦ ៥២៦ ២៤៩១ | ០៧៧ ៥០៨ ០៥៧<br>០១១ ៦៧០ ១៧៤ | | |
| ៨៤ | មណ្ឌលសុខភាពអូរស្មាច់ | ០១១ ៧៣៦ ៨៨៦ | | | |
| ៨៥ | មន្ទីរពេទ្យបង្អែក ១៦ មករា | ០១២ ៣៧១ ៦១៨ | ០១២ ៤២៦ ៥១៩<br>០១២ ៨៩២ ៩០៩ | | ព្រះវិហារ |
| ៨៦ | មណ្ឌលសុខភាពភ្នំដែក | ០៩២ ២២៧ ៦១៦ | ០៩៧ ៣៩៤ ៤៦៦៩<br>០៩២ ៩៥៦ ៥៦៩ | | |
| ៨៧ | មណ្ឌលសុខភាពជាំក្សាន្ដ | | ០១២ ៩៣៨ ១៥៩<br>០៩៧ ៧៥២ ៧៧៧៣ | | |
| ៨៨ | មណ្ឌលសុខភាពស្រអែម | | ០៩៩ ៣៥៨ ៤៤៧ | | |

# ដំណើរនៃការអភិវឌ្ឍន៍វិស័យសន្តិសុខសង្គម











**បេឡាជាតិរបបសន្តិសុខសង្គម**

National Social Security Fund

អាសយដ្ឋាន: អគារលេខ៣ មហាវិថីសហព័ន្ធរុស្សី
សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: (០២៣) ៨៨ ២៤ ៣៤ / ៩៩ ៨៤ ១៧
(០២៣) ៩៩ ៨៤ ១៨ / ៩៩ ៨៤ ១៩

Website: www.nssf.gov.kh

Email: info@nssf.gov.kh


**ទូរស័ព្ទទំនាក់ទំនងបន្ទាន់ ១២៨៦ បំរើសេវា ២៤ម៉ោង/៧ថ្ងៃ**